## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

# របាយការណ៍
# បូកសរុបលទ្ធផលការងារសុខភាពសត្វ និងផលិតកម្មសត្វ
# ប្រចាំឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២

ថ្ងៃទី២៦-២៧ ខែមករា ឆ្នាំ២០២២

រៀបចំដោយៈ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

ភូមិទ្រា ផ្លូវលេខ៣៧១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
Trea Village, Str371, Sangkat Steung Mean Chey, Khan Mean Chey, Phnom Penh Cambodia

ទូរស័ព្ទលេខ (៨៥៥) ២៣ ៨៨៣ ៧៤៦/៨៨៤ ១៤៨ ទូរសារ (៨៥៥) ២៣ ៨៨៣ ៧៤៦/៨៨៤ ១៤៨
Tel: (855) 23 883 746/884 148 Fax: (855) 23 883 746/884 148

# មាតិកា

ទំព័រ

I.**សេចក្តីផ្តើម**....................................................................................................០១
II.**គោលនយោបាយ និងយុទ្ធសាស្ត្រអនុវត្តរបស់រាជរដ្ឋាភិបាល**.............................០២
១.យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល.......................................០២
២.ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣.......................................០២
៣.ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា
ឆ្នាំ២០១៥-២០២៥.............................................................................................០២
៤.ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ២០១៦-២០២៥..........................០៣
៥.ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
២០២១-២០២៣ និង២០២២-២០២៤..........................................................................០៣
III.**លទ្ធផលជារួម**.....................................................................................................០៣
IV.**លទ្ធផលជំរុញផលិតកម្មសត្វ និងសុខភាពសត្វ**......................................................០៥
**១.ការជំរុញការចិញ្ចឹមសត្វ និងបង្កើនផលិតភាពសត្វ**.................................................០៥
១.១.ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ..........................................................................០៦
១.២.ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម.....................................................................០៦
១.៣.ស្ថិតិផលិតកម្មសត្វសរុបទូទាំងប្រទេស (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម)..................០៧
១.៤.ការប្រៀបធៀបបែបផែនផលិតកម្មសត្វ.....................................................................០៨
១.៥.តម្រូវការសត្វ និងសាច់............................................................................................១២
១.៦.ការនាំចេញសត្វ និងផលិតផលសត្វ..........................................................................១៣
១.៧.កម្មវិធីកែលម្អពូជ.................................................................................................១៣
១.៨.អំពីចំណីសត្វ.......................................................................................................១៤
១.៩.ការគ្រប់គ្រងកាកសំណល់សត្វ..................................................................................១៤
**២.ការលើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណៈ**..........................................១៥
២.១.ការលើកកម្ពស់សុខភាពសត្វ...................................................................................១៥
២.២.ការពង្រឹងសុខភាពសាធារណៈបសុព្យាបាល.............................................................១៦
**៣.ការផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម**..................................................................១៧
៣.១.ការងារផ្សព្វផ្សាយបច្ចេកទេស.................................................................................១៧
៣.២.ការងារនីតិកម្ម.....................................................................................................១៧
ក.លិខិតបទដ្ឋានគតិយុត្តដែលបានរៀបចំរួចរាល់.......................................................១៧
ខ.លិខិតបទដ្ឋានគតិយុត្តដែលកំពុងពិនិត្យ បន្តរៀបចំ និងពិភាក្សា.................................១៨
៣.៣.ការងារចេញលិខិតអនុញ្ញាត និងចុះបញ្ជិកា..........................................................១៨
៣.៤.ការងារស្រាវជ្រាវ និងអធិការកិច្ច..........................................................................១៩

**៤.ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ**................. ១៩
៤.១.ការងារស្រាវជ្រាវសុខភាពសត្វ..........................................................................១៩
ក.ការងារធ្វើរោគវិនិច្ឆ័យជំងឺសត្វ..........................................................................១៩
ខ.តាមដានភាពស៊ាំបសុឱសថប្រឆាំងនឹងមេរោគ......................................................២០
គ.វិភាគកាកសំណល់បសុឱសថ និងសារធាតុគីមីនៅក្នុងផលិតផលសត្វ.....................២០
៤.២.ការងារស្រាវជ្រាវផលិតកម្មសត្វ.......................................................................២១
ក.សេនេទិក និងការបង្កាត់ពូជសត្វ.........................................................................២១
ខ.ការវិភាគចំណីសត្វ.............................................................................................២១
**៥.ការពង្រឹងការផ្តល់សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ**.......................... ២២
៥.១.ការពង្រឹងការគ្រប់គ្រងអង្គភាព........................................................................២២
៥.២.ការអភិវឌ្ឍធនធានមនុស្ស..................................................................................២២
៥.៣.ការងាររៀបចំផែនការ..........................................................................................២២
៥.៤.ការពង្រឹងការផ្តល់សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ....................................២៣
៥.៥.ការងារសហប្រតិបត្តិការ..................................................................................... ២៤
ក.កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍....................................................................... ២៤
ខ.កិច្ចសហការជាតិ និងអង្គការសង្គមស៊ីវិល.............................................................២៤
គ.កម្មវិធី និងគម្រោងសំខាន់ៗកំពុងអនុវត្ត...............................................................២៤
V.**ភាពលទ្ធភាព និងបញ្ហាប្រឈម**.......................................................................២៤
VI.**ទិសដៅអនុវត្តឆ្នាំ២០២២**.................................................................................. ២៥
**១.សូចនាករទិសដៅ**................................................................................................ ២៥
**២.វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់**.................................................... ២៥
២.១.បង្កើនផលិតកម្មសត្វ........................................................................................២៥
២.២.បង្កើនសុខភាពសាធារណៈបសុព្យាបាល................................................................ ២៥
២.៣.បង្កើនប្រសិទ្ធភាពអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ............................២៥
២.៤.បង្កើនសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធ..................................................................២៦
២.៥.ចងក្រងសហគមន៍អ្នកចិញ្ចឹមសត្វ និងផលិតកម្មតាមកិច្ចសន្យា................................. ២៦
២.៦.ពង្រឹងការស្រាវជ្រាវ និងផ្សព្វផ្សាយ.................................................................... ២៦
២.៧.លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន.............................. ២៦
២.៨.បង្កបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការវិនិយោគ....................................២៦
២.៩.ពង្រឹងកិច្ចសហប្រតិបត្តិការកម្រិតជាតិ និងអន្តរជាតិ............................................. ២៦
VII.**សេចក្តីសន្និដ្ឋាន**................................................................................................ ២៧
VIII.**បញ្ជីឧបសម្ព័ន្ធ**................................................................................................២៩

# របាយការណ៍បូកសរុបលទ្ធផល
# ការងារសុខភាពសត្វ និងផលិតកម្មសត្វ ប្រចាំឆ្នាំ២០២១
# និងទិសដៅការងារឆ្នាំ២០២២

## I.សេចក្តីផ្តើម

អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វមានសក្តានុពលក្នុងការរួមចំណែកបង្កើតការងារ សន្តិសុខស្បៀង អាហារូបត្ថម្ភ កំណើនសេដ្ឋកិច្ច និងបានចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

ដោយយល់ឃើញថា អនុវិស័យនេះ បានចូលរួមចំណែកជួយទ្រទ្រង់សេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤វិស័យកសិកម្មត្រូវបានដាក់បញ្ចូលក្នុងចតុកោណទី ៤ មុំទី១ ចំណុចអាទិភាពទី៧ ចែងពីការជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីលើកកម្ពស់ការចិញ្ចឹមសត្វឱ្យកាន់តែទូលំទូលាយថែមទៀត តាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយផ្អែកលើខ្សែច្រវាក់តម្លៃ និងដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍអនុវិស័យនេះ ជាមួយគ្នានឹងការគិតគូដល់បញ្ហាសុវត្ថិភាពចំណីអាហារ លើកទឹកចិត្តដល់ការវិនិយោគរោងចក្រផលិតចំណីសត្វ កែលម្អការគ្រប់គ្រងសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និងផលិតផលសត្វ កិច្ចដំណើរការទីផ្សារ ជាពិសេសអនាម័យ និងភូតគាមអនាម័យ។ លើសពីនោះទៀត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ កំណត់ទិសដៅលើការជំរុញផលិតផលសាច់ក្នុងអត្រាកំណើន៣% ក្នុងមួយឆ្នាំ តាមរយៈការគ្រប់គ្រង និងការអភិវឌ្ឍការចិញ្ចឹមសត្វ កាត់បន្ថយហានិភ័យជំងឺឆ្លងសត្វ និងពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ។

ដើម្បីគាំទ្រដល់ទិសដៅអាទិភាពរបស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាដែលមានជាអាទិ៍៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រថវិកា២០២២-២០២៤ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ២០១៦-២០២៥ ផែនការសកម្មភាពអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម និងផែនការសកម្មភាពពាក់ព័ន្ធនានា។ ជារៀងរាល់ឆ្នាំអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យវាយតម្លៃវឌ្ឍនភាព និងសមិទ្ធផលសម្រេចបាននៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលបានដាក់ចេញ និងរកដំណោះស្រាយចំពោះបញ្ហាប្រឈម និងលើកទិសដៅសម្រាប់អនុវត្តឆ្នាំបន្ទាប់។

ដោយឡែកឆ្នាំនេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មិនត្រឹមតែពិនិត្យវាយតម្លៃលទ្ធផលប្រចាំឆ្នាំប៉ុណ្ណោះទេ ប៉ុន្តែក៏បានពិនិត្យនិន្នាការ និងលទ្ធផលការងារ៥ឆ្នាំចុងក្រោយ និងការអនុវត្តតាមអនុសាសន៍ណែនាំរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែងប្រជុំបូកសរុបការងារសុខភាពសត្វ និងផលិតកម្មសត្វឆ្នាំនេះ មានចរិកលក្ខណៈជាការបូកសរុបសមិទ្ធផលសំខាន់ៗនៃអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ដាក់ចេញនូវទិសដៅការងារអាទិភាពនៃអនុវិស័យនេះសម្រាប់ឆ្នាំបន្ទាប់ សំដៅឆ្លើយតបនឹងដំណើរការវិវឌ្ឍន៍រីកចម្រើននៃសេដ្ឋកិច្ចសង្គម និងវប្បធម៌ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ តំបន់ និងពិភពលោក។

តាមរយៈកិច្ចប្រជុំនេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានដាក់ចេញនូវយុទ្ធសាស្ត្រ ផែនការសកម្មភាព និងទិសដៅការងារអាទិភាពសម្រាប់ឱ្យគ្រប់នាយកដ្ឋាន វិទ្យាស្ថាន ការិយាល័យផលិតកម្ម និងបសុព្យាបាល រាជធានី ខេត្តទាំង២៥ សំដៅលើកកម្ពស់ការយល់ដឹងអំពីសុខភាពសត្វ និងផលិតកម្មសត្វ ប្រមូលផ្តុំកម្លាំងមហាជនពីគ្រប់មជ្ឈដ្ឋានឱ្យចូលរួមកាន់តែសកម្មថែមទៀត ក្នុងកិច្ចអភិវឌ្ឍន៍អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ការពារសុខភាពមនុស្ស សុខភាពសត្វ សុខុមាលភាពសត្វ និងបរិស្ថានតាមរយៈកម្មវិធីបង្ការ ទប់ស្កាត់និងលុបបំបាត់ជំងឺឆ្លងសត្វ និងជំងឺស៊ូណូស ដើម្បីធានានិរន្តរភាពនៃការផ្គត់ផ្គង់ផលិតផលសត្វប្រកបដោយគុណភាព និងសុវត្ថិភាពសម្រាប់តម្រូវការក្នុងស្រុក និងការនាំចេញ។

កិច្ចប្រជុំនេះ បានលើកយកនូវប្រធានបទសំខាន់មួយចំនួនសម្រាប់ធ្វើការពិភាក្សារួមមាន៖ (១).ស្ថានភាពផលិតកម្មសត្វឆ្នាំ២០២១ បញ្ហាប្រឈម និងកំណត់ទិសដៅឆ្នាំ២០២២ (២).ការពង្រឹងនីតិវិធីចេញលិខិតអនុញ្ញាត និងអធិការកិច្ចលើការធ្វើពាណិជ្ជកម្ម ការផលិត ការលាយផ្សំ បសុឱសថ និងចំណី (៣).អនុក្រឹត្យលេខ១០៨(ថ្មី) ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន និងការធ្វើអាជីវកម្មពិឃាតសត្វ (៤).យុទ្ធសាស្ត្រទប់ស្កាត់ជំងឺឆ្លងសត្វសំខាន់ៗ (៥).យុទ្ធសាស្ត្រជំរុញការកែលម្អការងារសត្តឃាតដ្ឋាន (៦).ការអនុវត្តអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វក្នុងបរិបទស្តីពីវិមជ្ឈការ និងវិសហមជ្ឈការការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៧).សុវត្ថិភាពចំណីអាហារដែលមានប្រភពមកពីសត្វ និង (៨).ជំងឺផ្តាសាយបក្សីនៅកម្ពុជា។

លទ្ធផលដែលសម្រេចបាននេះ អាស្រ័យដោយមានគោលនយោបាយត្រឹមត្រូវរបស់រាជរដ្ឋាភិបាលមានការគាំទ្រពីធនធានថវិកាជាតិ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ វិស័យឯកជន និងការខិតខំរបស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ដោយមានកិច្ចសហការល្អប្រសើរជាមួយការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានស្រុក អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ សហគមន៍ចិញ្ចឹមសត្វ សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា និងអ្នកពាក់ព័ន្ធ។

## II.គោលនយោបាយ និងយុទ្ធសាស្ត្រអនុវត្តរបស់រាជរដ្ឋាភិបាល

ដើម្បីធ្វើឱ្យសម្រេចនូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយចីរភាពរាជរដ្ឋាភិបាលបានដាក់ចេញនូវ៖

**១.យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល** លើកស្ទួយវិស័យកសិកម្មដែលក្នុងនោះបានកំណត់កម្មវិធីអាទិភាពលើកស្ទួយផលិតកម្មសត្វ និងសុខភាពសត្វ និងដាក់ចេញនូវទិសដៅចំនួន៤គឺ៖

ក.ជំរុញការរៀបចំ និងដាក់ឱ្យអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រលើកកម្ពស់ការចិញ្ចឹមសត្វ។

ខ.ជំរុញការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍លើការបង្កាត់ពូជ ការគ្រប់គ្រងសុខភាពសត្វ និងការផលិតចំណីសត្វ និងប្រព័ន្ធកសិដ្ឋាន។

គ.ជំរុញអនុម័តបទដ្ឋានក្រោមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីជាមូលដ្ឋានក្នុងគោលដៅពង្រឹងការអនុវត្តស្តង់ដារអនាម័យសត្វ សាច់ និងផលិតផលសត្វ បង្ការ ទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ និងជំងឺស៊ូណូស ដើម្បីការពារសុខភាពសត្វ សុខុមាលភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន។

ឃ.ជំរុញលើកទឹកចិត្តការវិនិយោគលើការផលិតចំណីសត្វ ដើម្បីគាំទ្រដល់ផលិតកម្មចិញ្ចឹមសត្វរួមជាមួយការលើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេស ពូជ ឥណទាន ការលើកទឹកចិត្តវិនិយោគឯកជនក្នុងការកែច្នៃផលិតផលសត្វ ការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងមានការសម្រួលពាណិជ្ជកម្មសត្វ និងផលិតផលសត្វ។

**២.ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣** បានកំណត់ទិសដៅគោលនយោបាយរបស់ក្រសួងសម្រាប់អនុវត្តរយៈពេល៥ឆ្នាំគឺ "ផលិតផលសាច់សរុបកើន៣%ក្នុងមួយឆ្នាំ បង្កើនអត្រានៃការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មពី២៣% នៅឆ្នាំ២០១៩ ដល់៣០% នៅឆ្នាំ២០២៣ និងកាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅក្រោម ៥% តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធកម្មភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្មដោយយកចិត្តទុកដាក់ខ្ពស់លើការការពារ និងគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព"។

**៣.ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥** ដើម្បីជំរុញការអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ក្នុងការរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្នតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រីកការប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។

ចំណុចគន្លឹះពាក់ព័ន្ធនឹងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ជាការតម្រង់ទិសការអភិវឌ្ឍន៍តំបន់កែច្នៃផលិតផលសត្វ ជាលក្ខណៈប្រមូលផ្តុំ ដែលមានសក្តានុពលសម្រាប់ប្រើប្រាស់ក្នុងស្រុក និងនាំចេញ។ យន្តការគន្លឹះដែលត្រូវយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍កសិឧស្សាហកម្មនោះ គឺការសម្របសម្រួល និងលើកទឹកចិត្តដល់វិស័យឯកជនក្នុងការវិនិយោគលើបច្ចេកទេសកែច្នៃផលិតផលសត្វស្របតាមស្តង់ដារផលិតផលអាស៊ាន និងតម្រូវការទីផ្សារអន្តរជាតិ។ ការផ្សារភ្ជាប់រវាងក្រុមអ្នកផលិតជាមួយអ្នកប្រមូលទិញតាមយន្តការ **"ផលិតកម្មកសិកម្មតាមកិច្ចសន្យា"** ដើម្បីធានាការផ្គត់ផ្គង់សាច់សត្វប្រកបដោយនិរន្តរភាព គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់។

បន្ថែមលើសពីនេះទៀត លើកកម្ពស់វិធានការអនាម័យ និងភូតគាមអនាម័យត្រូវបានយកចិត្តទុកដាក់លើការកសាងក្របខ័ណ្ឌគតិយុត្ត និងបច្ចេកវិទ្យា ព្រមទាំងពង្រីក និងពង្រឹងសមត្ថកិច្ចត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យនៅតាមច្រកព្រំដែន ដើម្បីសម្រួលពាណិជ្ជកម្ម និងធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក។

**៤.ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ២០១៦-២០២៥** ដែលដាក់ឱ្យអនុវត្តកាលពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៦ កន្លងមក បានកំណត់នូវចក្ខុវិស័យនៃក្របខ័ណ្ឌផែនការនេះគឺ "ការអភិវឌ្ឍន៍វិស័យបសុសត្វប្រកបដោយនិរន្តរភាព ធានាបាននូវសន្តិសុខស្បៀង សុវត្ថិភាពចំណីអាហារ និងការធ្វើពាណិជ្ជកម្មប្រកបដោយប្រាក់ចំណេញ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ"។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រនេះ ជំរុញឱ្យមានការអនុវត្តកម្មវិធីលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ តាមរយៈការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ការស្រាវជ្រាវនិងផ្សព្វផ្សាយ ការរៀបចំគោលនយោបាយ ការរៀបចំផែនការ ពង្រឹងការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ការអភិវឌ្ឍន៍ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ដែលមានទិសដៅអាទិភាពចំនួន០៨គឺ៖

១. ពង្រឹងផលិតកម្មសត្វ រួមទាំងលើកកម្ពស់ការគ្រប់គ្រង និងការបង្កាត់ពូជសត្វ។
២. ពង្រឹងសុខភាពសត្វ សុខភាពសាធារណៈបសុព្យាបាល និងសុខុមាលភាពសត្វ។
៣. លើកកម្ពស់ការផ្សព្វផ្សាយច្បាប់ ពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយនានា។
៤. ជំរុញការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ។
៥. បង្កើនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។
៦. លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជននៅក្នុងវិស័យអភិវឌ្ឍន៍បសុសត្វ។
៧. ពង្រឹងសេវាផ្សព្វផ្សាយសុខភាពសត្វ និងផលិតកម្មសត្វ និងការអភិវឌ្ឍទីផ្សារ។
៨. ពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និងបច្ចេកទេសកម្រិតជាតិ និងអន្តរជាតិលើអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

**៥.ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ២០២១-២០២៣ និង២០២២-២០២៤** បានត្រូវរៀបចំឡើងដោយឆ្លុះបញ្ចាំង និងឆ្លើយតបនឹងទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ ផែនការពាក់ព័ន្ធនានាត្រូវបានរៀបចំ និងកែលម្អ សំដៅគាំទ្រដល់គោលបំណងគោលនយោបាយរួមក្នុងការជំរុញកំណើនវិស័យកសិកម្មប្រចាំឆ្នាំឱ្យបានក្នុងរង្វង់៥% ដែលក្នុងនោះការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម គឺជាកម្មវិធីអាទិភាពមួយក្នុងចំណោមកម្មវិធីអាទិភាពទាំង៥ ក្នុងការជំរុញកំណើនក្នុងវិស័យកសិកម្ម។

កម្មវិធីលើកកម្ពស់ការចិញ្ចឹមសត្វបានកំណត់នូវសូចនាករច្បាស់លាស់គឺ ផលិតផលសាច់សរុបកើន៣% ក្នុងមួយឆ្នាំ តាមរយៈការលើកកម្ពស់ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម ការពង្រឹងសមត្ថភាព ពិសោធន៍ ស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសប្រកបដោយប្រសិទ្ធភាព កម្មវិធីបង្ការ ទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺស៊ូណូសដើម្បីធានាដល់ការផ្គត់ផ្គង់សត្វ និងផលិតផលសត្វប្រកបដោយអនាម័យ និងសុវត្ថិភាពឈានទៅបង្កើនសក្តានុពលនៃការនាំចេញ។

## III.លទ្ធផលជារួម

ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់ទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វត្រូវបានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាព ដែលសម្រេចបាននូវទិសដៅចំបងៗជាច្រើន ដើម្បីឆ្លើយតបទៅនឹងទិសដៅអាទិភាពនៃគោលនយោបាយក្នុងនោះរួមមាន៖

- កសាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងឯកសារគតិយុត្តនានា
- ពង្រឹងសមត្ថភាពអង្គភាព អភិវឌ្ឍន៍ធនធានមនុស្ស និងបង្កើនសមត្ថភាពដឹកនាំ គ្រប់គ្រង រៀបចំ និងអនុវត្ត ផែនការគម្រោងកម្មវិធី បង្កើនសមត្ថភាពបច្ចេកទេស រួមទាំងការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ និងការបំពាក់ឧបករណ៍សម្ភារមន្ទីរពិសោធន៍សម្រាប់អនុវត្តន៍តួនាទីភារកិច្ចស្នូលរបស់អង្គភាព
- ការកសាងផែនការ និងយុទ្ធសាស្ត្រនានាសម្រាប់អនុវត្តន៍ច្បាប់ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រសំខាន់ៗដែលរួមមានផែនការជាតិលុបបំបាត់ជំងឺអុតក្តាម ដែលស្ថិតក្នុងក្របខ័ណ្ឌនៃយុទ្ធនាការតំបន់ក្នុងការប្រយុទ្ធប្រឆាំង និងលុបបំបាត់ជំងឺអុតក្តាមនៃអង្គការសុខភាពសត្វពិភពលោក ផែនការសកម្មភាពទប់ស្កាត់ជំងឺសំខាន់ៗមានជំងឺញ្ញវកាស ជំងឺផ្តាសាយបក្សី ជំងឺអុតក្តាម ជំងឺសារទឹកគោ ក្របី ជំងឺជ្រូកត្រចៀកខៀវ ជំងឺប៉េស្តជ្រូកអាហ្វ្រិក ជំងឺដុំពកស្បែកគោ ក្របី ផែនការសកម្មភាពអនុវត្តសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០២២-២០២៤ និងការបង្កើតទម្រង់របាយការណ៍ឯកភាពទូទាំងប្រទេស ពាក់ព័ន្ធនឹងព័ត៌មានសុខភាពសត្វ និងផលិតកម្មសត្វ ដែលមានលក្ខណៈសាមញ្ញគ្រប់ជ្រុងជ្រោយ ហើយគ្របដណ្តប់លើប្រភេទទិន្នន័យសំខាន់ៗជាមូលដ្ឋានគ្រឹះសម្រាប់វិភាគ វាយតម្លៃ និងរៀបចំផែនការនានា
- ការកែទម្រង់ស៊ីជម្រៅក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វសម្រាប់គាំទ្រដល់ផលិតកម្មសត្វរួមជាមួយនឹងការលើកកម្ពស់ផ្តល់សេវាបច្ចេកទេស ពូជ ឥណទាន និងការសម្របសម្រួលទីផ្សារជូនផ្នែកឯកជននិងកសិករចិញ្ចឹមសត្វ ការកែច្នៃសាច់ ផលិតផលសត្វ និងការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងការសម្រួលដល់ការធ្វើពាណិជ្ជកម្មសត្វ និងផលិតផលសត្វ ការបង្កើតស្ថានីយ៍ចត្តាឡីស័កសត្វ កន្លែងត្រួតពិនិត្យសត្វ និងផលិតផលសត្វដើមទី និងចុងទី ការបង្កើតគណៈកម្មាការគ្រប់គ្រងហានិភ័យសុខភាពសត្វ និងផលិតកម្មសត្វ បំពេញតួនាទីត្រួតពិនិត្យប្រភពដើមសត្វ និងផលិតផលសត្វ ដើម្បីទប់ស្កាត់ជំងឺឆ្លងរាលដាលសត្វ ការពារសុខភាពសត្វ និងសុខភាពសាធារណៈ លើការនាំចូល នាំចេញ នាំឆ្លងកាត់សត្វ និងផលិតផលសត្វ ជាពិសេសកៀរគរវិស័យឯកជនឱ្យមកវិនិយោគក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងនាំចេញ
- ក្នុងឆ្នាំ២០២១ ប្រទេសកម្ពុជាក៏ដូចជាប្រទេសនានាក្នុងតំបន់ និងទូទាំងពិភពលោកបានទទួលរងនូវជំងឺផ្លូវដង្ហើមប្រភេទថ្មី (COVID-19) ដែលធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចជាតិទាំងមូល ជាពិសេសប្រជាពលរដ្ឋក្រីក្រ ដើម្បីចូលរួមកាត់បន្ថយនូវផលប៉ះពាល់ទាំងនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងដល់វិស័យកសិកម្ម ដោយបានផ្តល់អនុសាសន៍ "ត្រូវពិនិត្យលទ្ធភាពកាត់បន្ថយការនាំចូល និងបង្កើនការដាំដុះបន្លែ ចិញ្ចឹមត្រី និងសត្វជាដើម" និងគាំទ្រថវិកាតាមកម្មវិធី ដៃគូរអភិវឌ្ឍន៍ ព្រមទាំងមានការចូលរួមពីវិស័យឯកជន និងអ្នកពាក់ព័ន្ធនានាបានធ្វើឱ្យផលិតកម្មសត្វមានការកើនឡើង។

ដោយសារមានខឿនរឹងមាំនៃគោលនយោបាយ ច្បាប់ និងផែនការយុទ្ធសាស្ត្រមានលក្ខណៈគ្រប់ជ្រុងជ្រោយរួមជាមួយការអភិវឌ្ឍសមត្ថភាពអង្គភាព និងធនធានមនុស្សប្រកបដោយគុណភាព ការគ្រប់គ្រងអនុវិស័យនេះមិនត្រឹមតែជំនះបានគ្រប់នូវឧបសគ្គនានា ថែមទាំងសម្រេចបានសមិទ្ធផលសំខាន់ជាច្រើន។ ផលិតកម្មសត្វសរុបមានការកើនឡើង១១,២% បើប្រៀបធៀបទៅនឹងឆ្នាំ២០២០ ប៉ុន្តែថ្លៃដើមផលិត និងសេវាកម្មនានាខ្ពស់ ដែលមិនអាចប្រកួតប្រជែងជាមួយប្រទេសជិតខាងបាន បើទោះបីជាមានផ្ទុះជំងឺប៉េស្តជ្រូកអាហ្វ្រិក ជំងឺដុំពកស្បែកគោ ក្របី និងជំងឺផ្តាសាយបក្សីក៏ដោយ មន្ត្រីជំនាញបានចុះអន្តរាគមន៍ ពិនិត្យព្យាបាល ចាក់វ៉ាក់សាំង យកវត្ថុវិភាគ អនុវត្តវិធានជីវសុវត្ថិភាព អនុវត្តវិធានការបសុព្យាបាល អប់រំណែនាំ ផ្សព្វផ្សាយបច្ចេកទេសក្នុងការទប់ស្កាត់ជំងឺសំខាន់ៗបានទាន់ពេលវេលា។

ព្រឹត្តិការណ៍នេះបានប្រែក្លាយទៅជាកម្លាំងជំរុញឱ្យអ្នកចិញ្ចឹមសត្វមានបទពិសោធន៍ និងយល់ដឹងពីការជ្រើសរើសពូជល្អៗមកចិញ្ចឹមតាមរដូវកាលដែលធន់នឹងជំងឺ។

ការអនុវត្តគោលនយោបាយ ច្បាប់ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា ជាត្រីវិស័យធ្វើឱ្យអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សម្រេចបាននូវលទ្ធផលសំខាន់ៗជាច្រើន ដែលលទ្ធផលទាំងនោះស្តែងចេញតាមរយៈការកើនឡើងនូវការវិនិយោគលើផលិតផលចំណីសត្វ។ បច្ចុប្បន្ននេះមានក្រុមហ៊ុនវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វចំនួន២១ក្រុមហ៊ុន មានរោងចក្រ២៣កន្លែង និងរោងចក្រចំនួន២ទៀតកំពុងដំណើរការសាងសង់បន្ថែម។ ក្រុមហ៊ុនផលិតចំណីសត្វទាំងអស់ បាននិងកំពុងដំណើរការផលិតចំណីសត្វយ៉ាងសកម្ម ដោយផលិតចំណីសត្វបានប្រមាណជាង១,២៤លានតោន ស្មើនឹងចំនួន៥៥% នៃសមត្ថភាពផលិតរបស់រោងចក្រជាង២,២៧លានតោន។ សត្តឃាតដ្ឋាននៅក្នុងស្រុកសរុបមានចំនួន២៣៦កន្លែង ក្នុងនោះមានសត្តឃាតដ្ឋានពិឃាតគោទំនើបចំនួន១ និងសត្តឃាតដ្ឋានបក្សីទំនើបចំនួន១។ ការវិនិយោគបង្កើតកសិដ្ឋានចិញ្ចឹមជ្រូក បក្សី និងការចិញ្ចឹមគោយកទឹកដោះនិងផលិតទឹកដោះបានដំណើរការ។

ឆ្នាំ២០២១ នេះ ស្ថិតិសត្វចិញ្ចឹមសរុបបានកើនដល់៥៩,៩៦លានក្បាល បើធៀបនឹងឆ្នាំ២០២០ ចំនួន៥៣,៩០លានក្បាល គឺមានកំណើនចំនួន១១,២%។ ជាមួយនឹងកំណើននេះ កម្ពុជាអាចផ្គត់ផ្គង់សាច់បានចំនួន៨៧% ស្មើនឹង២៦៨ពាន់តោន ដែលតម្រូវការជាក់ស្តែងចំនួន៣១០ពាន់តោន។

ក្នុងឆ្នាំ២០២១ នេះ ដោយមានការត្រៀមលក្ខណៈបានល្អ និងយកចិត្តទុកដាក់ខ្ពស់លើការងារអង្កេតតាមដានស្រាវជ្រាវប្រភពចម្លងជំងឺ និងមានប្រព័ន្ធរាយការណ៍ស្ថានភាពសុខភាពសត្វជាប្រចាំ ករណីផ្ទុះជំងឺឆ្លងត្រូវបានរកឃើញ និងរាយការណ៍បានឆាប់រហ័ស និងបានចាត់វិធានការឆ្លើយតបទាន់ពេលវេលា។ ក្នុងឆ្នាំនេះដែរ ការធ្វើបង្ហាញអំពីការអនុវត្តការចិញ្ចឹមសត្វល្អ បានត្រូវជំរុញនៅទូទាំងប្រទេសជាមួយការរីកចម្រើនក្នុងការពង្រឹងចងក្រងសហគមន៍ចិញ្ចឹមសត្វ ដើម្បីងាយស្រួលក្នុងការផ្តល់ការគាំទ្របច្ចេកទេស និងទទួលបានព័ត៌មានទីផ្សារសត្វ។

## IV.លទ្ធផលជំរុញផលិតកម្មសត្វ និងសុខភាពសត្វ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មានតួនាទីធានាការគ្រប់គ្រង និងអភិវឌ្ឍន៍អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ការពារសុខភាពសាធារណៈ សុខភាពសត្វ សុខុមាលភាពសត្វ និងការពារបរិស្ថាន បង្ការទប់ស្កាត់ លុបបំបាត់ជំងឺឆ្លងរាលដាលសត្វ ការពារធនធានសត្វ និងពូជសត្វរបស់ជាតិ ព្រមទាំងធានានូវនិរន្តរភាពនៃការផ្គត់ផ្គង់សត្វ និងផលិតផលសត្វ ប្រកបដោយគុណភាព និងសុវត្ថិភាពសម្រាប់ទីផ្សារក្នុងស្រុក និងការនាំចេញ។

### ១.ការជំរុញការចិញ្ចឹមសត្វ និងបង្កើនផលិតភាពសត្វ

ផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ បានកំណត់សូចនាករសំខាន់ចំនួន០៣សម្រាប់អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វគឺ ១).ផលិតផលសាច់សរុបកើន៣% ក្នុងមួយឆ្នាំ ២).អត្រានៃការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មកើនឡើងពី២៣% នៅឆ្នាំ២០១៩ ដល់៣០% នៅឆ្នាំ២០២៣ និង៣).កាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅក្រោម៥%។

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វឆ្នាំ២០១៦-២០២៥ គាំទ្រដល់អ្នកចិញ្ចឹមសត្វខ្នាតតូច និងជំរុញការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្ម តាមរយៈការកែលម្អការចិញ្ចឹមសត្វលក្ខណៈគ្រួសារ ជំរុញការកែលម្អពូជសត្វ ការបង្កាត់ពូជសត្វ និងផលិតកម្មចំណីសត្វ ការសម្របសម្រួល និងការជំរុញអនុវត្តការចិញ្ចឹមសត្វល្អ (GAHP) ការតាមដាន និងត្រួតពិនិត្យគុណភាពចំណីសត្វ ការគ្រប់គ្រងកាកសំណល់សត្វ ការពង្រឹងការគ្រប់គ្រងទិន្នន័យស្ថិតិផលិតកម្មសត្វ និងអត្តសញ្ញាណកម្មសត្វ ជំរុញការវិនិយោគបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និងវិនិយោគលើការផលិតចំណីសត្វ ដោយបានផ្តល់ការគាំទ្រ និងបង្កបរិយាកាសអនុគ្រោះដល់ការវិនិយោគ។ ជាក់ស្តែងក្នុងឆ្នាំ២០២១ សម្រេចបានលទ្ធផលសំខាន់ៗរួមមាន៖

## ១.១.ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារក្នុងឆ្នាំ២០២១ មានចំនួនសរុប៣៦,៥៧លានក្បាល ក្នុងនោះមានគោចំនួន ២,៩៥លានក្បាល ក្របីចំនួន៤៣២ពាន់ក្បាល ជ្រូកចំនួន១,២៥លានក្បាល បក្សីចំនួន៣១,៨៩លានក្បាល សេះចំនួន៣,៥៨ពាន់ក្បាល ចៀមចំនួន២,៤៩ពាន់ក្បាល ពពែចំនួន៤២,៥ពាន់ក្បាល និងដំរីចំនួន៤៩ក្បាល (ឧបសម្ព័ន្ធទី១ ទី១.១ ទី១.២ និងទី១.៣)។

បើប្រៀបធៀបឆ្នាំ២០២០ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសរុបកើនឡើងចំនួន៤,៦% ក្នុងនោះគោកើនចំនួន ៤,១% ក្របីកើនចំនួន២,១% គោ ក្របីកើនចំនួន៣,៩% ជ្រូកកើនចំនួន៩,៩% បក្សីកើនចំនួន៤,៤% សេះកើនចំនួន ២០,៦% ចៀមកើនចំនួន១៦៤,១% និងពពែកើនចំនួន៤១,៨% (ឧបសម្ព័ន្ធទី១.៤)។

### តារាងស្ថិតិផលិតកម្មសត្វ លក្ខណៈគ្រួសារ ពីឆ្នាំ២០១៧-២០២១

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀប |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | (២០២១&២០២០) |
| ១ | គោ | ២ ៩៥១ ៣៥៩ | ២ ៩១៧ ៣០២ | ២ ៧៦៩ ៨៨៥ | ២ ៨៣៥ ៣៦០ | ២ ៩៥២ ៧៥១ | ៤,១% |
| ២ | ក្របី | ៥០៨ ៤៥៨ | ៥០០ ៧៧៨ | ៤៤៧ ១៦៧ | ៤២៣ ៦១៤ | ៤៣២ ៤០៩ | ២,១% |
| ៣ | គោ ក្របី | ៣ ៤៥៩ ៨១៧ | ៣ ៤១៨ ០៨០ | ៣ ២១៧ ០៥២ | ៣ ២៥៨ ៩៧៤ | ៣ ៣៨៥ ១៦០ | ៣,៩% |
| ៤ | កម្លាំងអូសទាញ | ៩៣៥ ២៣៩ | ៨៣៦ ៣០១ | ៧១៧ ៩០២ | ៦៤៨ ៧២៩ | ១៦១ ៥៥០ | -៧៥,១% |
| ៥ | ជ្រូក | ២ ៣៣១ ៥១២ | ១ ៩៣៤ ៩១៧ | ១ ០៣០ ៤៩៤ | ១ ១៣៧ ០៥៦ | ១ ២៥០ ១៦៧ | ៩,៩% |
| ៦ | បក្សី | ២៨ ៦៥២ ៤០៩ | ២៨ ៩៥៦ ៣៤២ | ២៧ ៧៦៣ ៤៧៩ | ៣០ ៥៥៣ ២៣៣ | ៣១ ៨៩១ ៩៥២ | ៤,៤% |
| ៧ | សេះ | ៥ ០៥៥ | ៤ ២០៧ | ៣ ៧៧១ | ២ ៩៧១ | ៣ ៥៨៣ | ២០,៦% |
| ៨ | ចៀម | ៤៦១ | ៤៥៩ | ៦៤៨ | ៩៤៤ | ២ ៤៩៣ | ១៦៤,១% |
| ៩ | ពពែ | ២៨ ៥៤២ | ២៥ ៧៤៧ | ២៧ ៧៤០ | ២៩ ៩៨១ | ៤២ ៥០៦ | ៤១,៨% |
| ១០ | ដំរី | ៦៣ | ៥៨ | ១៨ | ៥១ | ៤៩ | -៣,៩% |
| ១១ | ស្វា | | | ១៤៨ | ២១៩ | ១៦៦ | -២៤,២% |
| ១២ | ទន្សាយ | | | ១៨៥ | ៣១១ | ៥៤៦ | ៧៥,៦% |
| សរុប | | ៣៤ ៤៧៧ ៨៥៩ | ៣៤ ៣៣៩ ៨១០ | ៣២ ០៤៣ ៥៣៥ | ៣៤ ៩៨៣ ៧៤០ | ៣៦ ៥៧៦ ៦២២ | ៤,៦% |




## ១.២.ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

សត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មក្នុងឆ្នាំ២០២១ មានចំនួនសរុប២៣,៣៨លានក្បាល ក្នុងនោះគោ ក្របីចំនួន១៤,៧៩ពាន់ក្បាល ជ្រូកចំនួន១,៧៦លានក្បាល បក្សីចំនួន២១,៥៣លានក្បាល ចៀមចំនួន១,៨៣ពាន់ក្បាល ពពែចំនួន១,០៥ពាន់ក្បាល និងស្វាចំនួន៦៨ពាន់ក្បាល (ឧបសម្ព័ន្ធទី២ ២.១ ២.២ ២.៣ ២.៤ ២.៥ ២.៦ និងទី២.៧)។

បើប្រៀបធៀបឆ្នាំ២០២០ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មសរុបកើនឡើងចំនួន២៣,៦% ក្នុងនោះគោក្របីកើនចំនួន១០,២% ជ្រូកកើនចំនួន២៨,២% បក្សីកើនចំនួន២៣,0% ចៀមកើនចំនួន១៣០,៥% ពពែកើនចំនួន២៥១,៧% និងស្វាកើនចំនួន២៩៩,៨% (ឧបសម្ព័ន្ធទី២.៨)។

### ស្ថិតិផលិតកម្មសត្វ លក្ខណៈពាណិជ្ជកម្ម ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀប (២០២១&២០២០) |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| ១ | គោ | ២០ ៣៦៣ | ១១ ២៣២ | ៩ ៨៧៧ | ១៣ ២១៦ | ១៤ ៦៤៧ | ១០,៨% |
| ២ | ក្របី | ១៩៨ | ២១៧ | ២១៨ | ២១១ | ១៥០ | -២៨,៩% |
| ៣ | គោ-ក្របី | ២០ ៥៦១ | ១១ ៤៤៩ | ១០ ០៩៥ | ១៣ ៤២៧ | ១៤ ៧៩៧ | ១០,២% |
| ៤ | ជ្រូក | ៧៤២ ៧៧១ | ៨១២ ៩៣៨ | ១ ១៥៥ ៤៣១ | ១ ៣៧៩ ៦២៣ | ១ ៧៦៨ ៦៣០ | ២៨,២% |
| ៥ | បក្សី | ៧ ៥៩២ ៥៣០ | ៩ ២១០ ៤០៩ | ១២ ៦៣១ ៩៧៤ | ១៧ ៥០៨ ៩៣៦ | ២១ ៥៣០ ៧៥២ | ២៣,0% |
| ៦ | សេះ | ៨២ | ៨៩ | ៣០ | 0 | 0 | 0% |
| ៧ | ចៀម | 0 | 0 | 0 | ៧៨១ | ១ ៨០០ | ១៣០,៥% |
| ៨ | ពពែ | ៣៦៥ | ៧០០ | 0 | ៣០០ | ១ ០៥៥ | ២៥១,៧% |
| ៩ | ស្វា | - | - | ១៤ ០៧៩ | ១៧ ០១០ | ៦៨ ០០០ | ២៩៩,៨% |
| ១០ | ទន្សាយ | - | - | - | 0 | 0 | 0 |
| សរុប | | ៨ ៣៥៦ ៣០៩ | ១០ ០៣៥ ៥៨៥ | ១៣ ៨១១ ៦០៨ | ១៨ ៩២០ ០៧៧ | ២៣ ៣៨៥ ០៣៤ | ២៣,៦% |




### ១.៣.ស្ថិតិផលិតកម្មសត្វសរុបទូទាំងប្រទេស (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម)

ជារួមផលិតកម្មសត្វគ្រប់ប្រភេទក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន៤២,៨៣លានក្បាល ក្នុងឆ្នាំ២០១៧ កើនដល់ចំនួន៥៩,៩៦លានក្បាល នៅឆ្នាំ២០២១។ ដោយឡែកក្នុងឆ្នាំ២០២១ នេះ ស្ថិតិសត្វគោមានចំនួន២,៩៦លានក្បាល ក្របីចំនួន៤៣២,៥៥ពាន់ក្បាល ជ្រូកចំនួន៣,០១លានក្បាល បក្សីចំនួន៥៣,៤២លានក្បាល សេះចំនួន៣,៥៨ពាន់ក្បាល ចៀមចំនួន៤,២៩ពាន់ក្បាល ពពែចំនួន៤៣,៥៦ពាន់ក្បាល ដំរីចំនួន៤៩ក្បាល ស្វាចំនួន៦៨,១៦ពាន់ក្បាល និងទន្សាយចំនួន៥៤៦ក្បាល (ឧបសម្ព័ន្ធទី៣)។

បើប្រៀបធៀបទៅនឹងឆ្នាំ២០២០ ផលិតកម្មសត្វសរុបមានអត្រាកំណើនចំនួន១១,២% ក្នុងនោះគោកើនចំនួន ៤,២% ក្របីកើនចំនួន២,១% ជ្រូកកើនចំនួន២០,០% បក្សីកើនចំនួន១១,២% សេះកើនចំនួន២០,៦% ចៀមកើនចំនួន១៤៨,៩% ពពែកើនចំនួន៤៣,៩% ស្វាកើនចំនួន២៩៥,៦% ទន្សាយកើនចំនួន៧៥,៦% ដោយឡែកដំរីថយចុះចំនួន(-៣,៩%) (ឧបសម្ព័ន្ធទី៤)។

### តារាងស្ថិតិផលិតកម្មសត្វសរុប ចិញ្ចឹមជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម ពីឆ្នាំ២០១៧-២០២១

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀប ឆ្នាំ២០២១ &២០២០ | អត្រាកំណើនមធ្យម ៥ឆ្នាំ |
|---|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | | |
| ១ | គោ | ២ ៩៧១ ៧២២ | ២ ៩២៨ ៥៣៤ | ២ ៧៧៩ ៧៦២ | ២ ៨៤៨ ៥៧៦ | ២ ៩៦៧ ៣៩៨ | ៤,២% | ០,៤% |
| ២ | ក្របី | ៥០៨ ៦៥៦ | ៥០០ ៩៩៥ | ៤៤៧ ៣៨៥ | ៤២៣ ៨២៥ | ៤៣២ ៥៥៩ | ២,១% | -៣,៦% |
| ៣ | គោ ក្របី | ៣ ៤៨០ ៣៧៨ | ៣ ៤២៩ ៥២៩ | ៣ ២២៧ ១៤៧ | ៣ ២៧២ ៤០១ | ៣ ៣៩៩ ៩៥៧ | ៣,៩% | -០,២% |
| ៤ | កម្លាំងអូសទាញ | ៩៣៥ ២៣៩ | ៨៣៦ ៣០១ | ៧១៧ ៩០២ | ៦៤៨ ៧២៩ | ១៦១ ៥៥០ | -៧៥,១% | -២៤,១% |
| ៥ | ជ្រូក | ៣ ០៧៤ ២៨៣ | ២ ៧៤៧ ៨៥៥ | ២ ១៨៥ ៩២៤ | ២ ៥១៦ ៦៧៩ | ៣ ០១៨ ៧៩៧ | ២០,០% | ១,៥% |
| ៦ | បក្សី | ៣៦ ២៤៤ ៩៣៩ | ៣៨ ១៦៦ ៧៥១ | ៤០ ៣៩៥ ៤៥៣ | ៤៨ ០៦២ ១៦៩ | ៥៣ ៤២២ ៧០៤ | ១១,២% | ៨,៥% |
| ៧ | សេះ | ៥ ១៣៧ | ៤ ២៩៦ | ៣ ៨០១ | ២ ៩៧១ | ៣ ៥៨៣ | ២០,៦% | -៧,៧% |
| ៨ | ចៀម | ៤៦១ | ៤៥៩ | ៦៤៨ | ១ ៧២៥ | ៤ ២៩៣ | ១៤៨,៩% | ៧០,៩% |
| ៩ | ពពែ | ២៨ ៩០៧ | ២៦ ៤៤៧ | ២៧ ៧៤០ | ៣០ ២៨១ | ៤៣ ៥៦១ | ៤៣,៩% | ៩,៨% |
| ១០ | ដំរី | ៦៣ | ៥៨ | ១៨ | ៥១ | ៤៩ | -៣,៩% | ២០,៥% |
| ១១ | ស្វា | - | - | ១៤ ២២៨ | ១៧ ២២៩ | ៦៨ ១៦៦ | ២៩៥,៦% | ៦៣,៣% |
| ១២ | ទន្សាយ | - | - | ១៨៥ | ៣១១ | ៥៤៦ | ៧៥,៦% | ២៨,៧% |
| សរុប | | ៤២ ៨៣៤ ១៦៨ | ៤៤ ៣៧៥ ៣៩៥ | ៤៥ ៨៥៥ ១៤៣ | ៥៣ ៩០៣ ៨១៧ | ៥៩ ៩៦១ ៦៥៦ | ១១,២% | ៧,៥% |




## ១.៤.ការប្រៀបធៀបបែបផែនផលិតកម្មសត្វ

ការជំរុញផលិតកម្មសត្វ និងបង្កើនផលិតភាពសត្វ គឺជាគោលដៅអាទិភាពសម្រាប់ការធ្វើពាណិជ្ជកម្មសត្វ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម មានអត្រាកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន៨,៣៥លានក្បាល ក្នុងឆ្នាំ២០១៧ កើនដល់ចំនួន២៣,៣៨លានក្បាល នៅឆ្នាំ២០២១។ ដោយឡែកក្នុងឆ្នាំ

២០២១ នេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានអត្រាកំណើនចំនួន២៣,៦% ក្នុងនោះផលិតកម្មគោកើនចំនួន ១០,៨% ផលិតកម្មជ្រូកកើនចំនួន២៨,២% និងផលិតកម្មបក្សីកើនចំនួន២៣,០%។ អត្រានៃកំណើននេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមានមួយ ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែល្អប្រសើរឡើង។

+ **ការប្រៀបធៀបបែបផែនផលិតកម្មសត្វ៖** អត្រានៃការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន៣៥% ក្នុងឆ្នាំ២០២០ ដល់ចំនួន៣៩% នៅឆ្នាំ២០២១។ ដោយឡែកអត្រានៃការចិញ្ចឹមសត្វលក្ខណៈគ្រួសារបានថយចុះពីចំនួន៦៥% ក្នុងឆ្នាំ២០២០ មកត្រឹមចំនួន៦១% នៅឆ្នាំ២០២១។

## ស្ថិតិសត្វសរុប តាមបែបផែនផលិតកម្ម ពីឆ្នាំ២០១៧-២០២១

| បែបផែន ផលិតកម្មសត្វ | ស្ថិតិសត្វសរុប ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀបឆ្នាំ ២០២១ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| លក្ខណៈគ្រួសារ | ៣៤ ៤៧៧ ៨៥៩ | ៣៤ ៣៣៩ ៨១០ | ៣២ ០៤៣ ៥៣៥ | ៣៤ ៩៨៣ ៧៤០ | ៣៦ ៥៧៦ ៦២២ | ៤,៦% |
| លក្ខណៈពាណិជ្ជកម្ម | ៨ ៣៥៦ ៣០៩ | ១០ ០៣៥ ៥៨៥ | ១៣ ៨១១ ៦០៨ | ១៨ ៩២០ ០៧៧ | ២៣ ៣៨៥ ០៣៤ | ២៣,៦% |
| **សរុប** | **៤២ ៨៣៤ ១៦៨** | **៤៤ ៣៧៥ ៣៩៥** | **៤៥ ៨៥៥ ១៤៣** | **៥៣ ៩០៣ ៨១៧** | **៥៩ ៩៦១ ៦៥៦** | **១១,២%** |




## អត្រានៃបែបផែនផលិតកម្មសត្វសរុប ពីឆ្នាំ២០១៧-២០២១

| បែបផែន ផលិតកម្មសត្វ | អត្រានៃបែបផែនផលិតកម្មសត្វសរុប ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀបឆ្នាំ ២០២១ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| លក្ខណៈគ្រួសារ | ៨០% | ៧៧% | ៧០% | ៦៥% | ៦១% | -៤% |
| លក្ខណៈពាណិជ្ជកម្ម | ២០% | ២៣% | ៣០% | ៣៥% | ៣៩% | ៤% |



+ **ការប្រៀបធៀបបែបផែនផលិតកម្មជ្រូក៖** អត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន ៥៥% ក្នុងឆ្នាំ២០២០ ដល់ចំនួន៥៩% នៅក្នុងឆ្នាំ២០២១។ ដោយឡែកអត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ បានថយចុះពីចំនួន៤៥% ក្នុងឆ្នាំ២០២០ មកត្រឹមចំនួន៤១% នៅឆ្នាំ២០២១។

### ស្ថិតិជ្រូក តាមបែបផែនផលិតកម្ម ពីឆ្នាំ២០១៧-២០២១

| បែបផែន ផលិតកម្មជ្រូក | ស្ថិតិជ្រូក ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀបឆ្នាំ ២០២១ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| លក្ខណៈគ្រួសារ | ២ ៣៣១ ៥១២ | ១ ៩៣៤ ៩១៧ | ១ ០៣០ ៤៩៤ | ១ ១៣៧ ០៥៦ | ១ ២៥០ ១៦៧ | ៩,៩% |
| លក្ខណៈពាណិជ្ជកម្ម | ៧៤២ ៧៧១ | ៨១២ ៩៣៨ | ១ ១៥៥ ៤៣១ | ១ ៣៧៩ ៦២៣ | ១ ៧៦៨ ៦៣០ | ២៨,២% |
| **សរុប** | **៣ ០៧៤ ២៨៣** | **២ ៧៤៧ ៨៥៥** | **២ ១៨៥ ៩២៤** | **២ ៥១៦ ៦៧៩** | **៣ ០១៨ ៧៩៧** | **២០,០%** |




### អត្រានៃស្ថិតិជ្រូក តាមបែបផែនផលិតកម្ម ពីឆ្នាំ២០១៧-២០២១

| បែបផែន ផលិតកម្មជ្រូក | អត្រានៃបែបផែនផលិតកម្មជ្រូក ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀបឆ្នាំ ២០២១ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| លក្ខណៈគ្រួសារ | ៧៦% | ៧០% | ៤៧% | ៤៥% | ៤១% | -៤% |
| **លក្ខណៈពាណិជ្ជកម្ម** | **២៤%** | **៣០%** | **៥៣%** | **៥៥%** | **៥៩%** | **៤%** |



+ **ការប្រៀបធៀបបែបផែនផលិតកម្មបក្សី៖** អត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន ៣៦% ក្នុងឆ្នាំ២០២០ ដល់ចំនួន៤០% នៅឆ្នាំ២០២១។ ដោយឡែកអត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារបានថយចុះពីចំនួន៦៤% ក្នុងឆ្នាំ២០២០ មកត្រឹមចំនួន៦០% នៅឆ្នាំ២០២១។

## ស្ថិតិបក្សី តាមបែបផែនផលិតកម្ម ពីឆ្នាំ២០១៧-២០២១

| បែបផែន ផលិតកម្មបក្សី | ស្ថិតិបក្សី ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀបឆ្នាំ ២០២១ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| លក្ខណៈគ្រួសារ | ២៨ ៦៥២ ៤០៩ | ២៨ ៩៥៦ ៣៤២ | ២៧ ៧៦៣ ៤៧៩ | ៣០ ៥៥៣ ២៣៣ | ៣១ ៨៩១ ៩៥២ | ៤,៤% |
| លក្ខណៈពាណិជ្ជកម្ម | ៧ ៥៩២ ៥៣០ | ៩ ២១០ ៤០៩ | ១២ ៦៣១ ៩៧៤ | ១៧ ៥០៨ ៩៣៦ | ២១ ៥៣០ ៧៥២ | ២៣,០% |
| **សរុប** | **៣៦ ២៤៤ ៩៣៩** | **៣៨ ១៦៦ ៧៥១** | **៤០ ៣៩៥ ៤៥៣** | **៤៨ ០៦២ ១៦៩** | **៥៣ ៤២២ ៧០៤** | **១១,២%** |




## អត្រានៃបែបផែនផលិតកម្មបក្សី ពីឆ្នាំ២០១៧-២០២១

| បែបផែន ផលិតកម្មបក្សី | អត្រានៃបែបផែនផលិតកម្មបក្សី ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀបឆ្នាំ ២០២១ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| លក្ខណៈគ្រួសារ | ៧៩% | ៧៦% | ៦៩% | ៦៤% | ៦០% | -៤% |
| លក្ខណៈពាណិជ្ជកម្ម | ២១% | ២៤% | ៣១% | ៣៦% | ៤០% | ៤% |



## ១.៥.តម្រូវការសត្វ និងសាច់

ផ្អែកតាមការសិក្សារបស់អង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ ការបរិភោគសាច់សត្វនៅកម្ពុជា មនុស្សម្នាក់ក្នុងមួយឆ្នាំហូបសាច់ជាមធ្យមប្រមាណ១៨គីឡូក្រាម ក្នុងនោះមានសាច់គោ ក្របីចំនួន០៥គីឡូក្រាម សាច់ជ្រូកចំនួន៩,២៩គីឡូក្រាម សាច់បក្សីចំនួន៣,៦៩គីឡូក្រាម និងសាច់ចៀម ពពែចំនួន០,០២គីឡូក្រាម។

ក្នុងរយៈពេល០៥ឆ្នាំចុងក្រោយនេះ តម្រូវការសាច់សត្វសម្រាប់ការបរិភោគ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពីចំនួន២៨០ពាន់តោន ក្នុងឆ្នាំ២០១៧ ឡើងដល់ចំនួន៣១០ពាន់តោន នៅឆ្នាំ២០២១។ ដោយឡែកក្នុងឆ្នាំ ២០២១ នេះ តម្រូវការសាច់មានចំនួនសរុប៣១០ពាន់តោន ក្នុងនោះសាច់គោ-ក្របីចំនួន៨៦ពាន់តោន សាច់ជ្រូកចំនួន ១៦០ពាន់តោន សាច់បក្សីចំនួន៦៣ពាន់តោន និងសាច់ចៀម-ពពែ ឬសាច់ផ្សេងទៀតចំនួន៣៤៥តោន។ ផលិតកម្មសត្វក្នុងស្រុកអាចផ្គត់ផ្គង់សាច់បានប្រមាណ២៦៨ពាន់តោន ឬស្មើនឹង៨៧% នៃតម្រូវការសរុប ក្នុងនោះសាច់គោ-ក្របីចំនួន ៨៩ពាន់តោន (៨១៥ពាន់ក្បាល) សាច់ជ្រូកចំនួន១១៥ពាន់តោន (២ ៣១០ពាន់ក្បាល) សាច់បក្សីចំនួន៦៣ពាន់តោន (៥២ ៩៤១ពាន់ក្បាល)។ បរិមាណសាច់ដែលខ្វះខាតត្រូវបាននាំចូលដើម្បីបំពេញតម្រូវការបន្ថែមជាក់ស្តែងនៅក្នុងឆ្នាំ២០២១ កម្ពុជាបាននាំចូលសាច់ និងផលិតសត្វមួយចំនួនរួមមានជ្រូកសាច់រស់ចំនួន៧០៩ពាន់ក្បាល មាន់សាច់រស់ចំនួន៣,៨៣លានក្បាល ទាសាច់រស់ចំនួន៧៣៤ពាន់ក្បាល ចៀម-ពពែរស់ចំនួន៦ពាន់ក្បាល និងសាច់ចម្រុះចំនួន៧,៤២ពាន់តោន (សាច់ជ្រូក ចៀម មាន់ ទា ក្ងាន ក្រួច ព្រាប គោ ក្របី ប្រហិត និងផលិតផលសាច់សត្វ) (ឧបសម្ព័ន្ធទី៥)។

### តារាងតម្រូវការប្រើប្រាស់ ការផ្គត់ផ្គង់ និងការបំពេញបន្ថែម ឆ្នាំ២០២១

| ប្រភេទសត្វ | តម្រូវការប្រើប្រាស់ | | លទ្ធភាពផ្គត់ផ្គង់ក្នុងស្រុក | | លើស/ខ្វះ(+/-) | |
|---|---|---|---|---|---|---|
| | សាច់ (តោន) | សត្វ (ពាន់ក្បាល) | សាច់ (តោន) | សត្វ (ពាន់ក្បាល) | សាច់ (តោន) | សត្វ (ពាន់ក្បាល) |
| គោ ក្របី | ៨៦ ១៣៣ | ៧៨៣ | ៨៩ ៦៨៨ | ៨១៥ | ៣ ៥៥៤ | ៣២ |
| ជ្រូក | ១៦០ ០៣៦ | ៣ ២០១ | ១១៥ ៤៩០ | ២៣១០ | -៤៤ ៥៤៦ | -៨៩១ |
| បក្សី | ៦៣ ៥៦៧ | ៥២ ៩៧២ | ៦៣ ៥២៩ | ៥២៩៤១ | -៣៨ | -៣១ |
| ចៀម ពពែ & ផ្សេងៗ | ៣៤៥ | ៣៤ | ១៨៣ | ១៨ | -១៦២ | -១៦ |
| សរុប | ៣១០ ០៨១ | | ២៦៨ ៨៩០ | ស្មើនឹង ៨៧% | -៤១ ១៩១ | ស្មើនឹង ១៣% |






## ១.៦.ការនាំចេញសត្វ និងផលិតផលសត្វ

កម្ពុជាមានលទ្ធភាពធ្វើការនាំចេញគោ ក្របី ជ្រូក មាន់ ស្វាក្តាម សាច់ ផលិតផលសត្វ ចំណីសត្វ និងទឹកដោះគោមួយចំនួនទៅបរទេសផងដែរ។ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ កម្ពុជាបាននាំចេញគោ ក្របីចំនួន៨៨,៦ពាន់ក្បាល ជ្រូកពូជ (មេ,បា,កូន) ចំនួន៧,៧ពាន់ក្បាល ស្វាក្តាមចំនួន៨០,៦ពាន់ក្បាល សាច់គោចំនួន១៩តោន ទឹកដោះគោចំនួន១២,៣ពាន់តោន ចំណីឆ្អែចំនួន១១ពាន់តោន រោមសត្វចំនួន៧៤,៨តោន និងស្បែកគោ ក្របី ជ្រូកចំនួន៧,៧ពាន់តោន។ ដោយឡែកនៅឆ្នាំ២០២១ បាននាំចេញគោ ក្របីចំនួន៤,៦ពាន់ក្បាល ជ្រូកពូជចំនួន៧១៧ក្បាល ស្វាក្តាមចំនួន២៣,២ពាន់ក្បាល ទឹកដោះគោចំនួន៣៨១តោន ចំណីឆ្អែចំនួន៤,៨ពាន់តោន រោមសត្វចំនួន១២តោន និងស្បែកគោ ក្របី ជ្រូកចំនួន១,០៥ពាន់តោន។

**តារាងស្ថិតិនាំចេញសត្វ សាច់ ផលិតផលសត្វ និងចំណីសត្វ ពីឆ្នាំ២០១៧-២០២១**

| បរិយាយ | ឯកតា | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | សរុប |
|---|---|---|---|---|---|---|---|
| គោ-ក្របី | ក្បាល | ១១ ២៤០ | ៦ ៧៨៦ | ៥៦ ២១៨ | ៩ ៧៤២ | ៤ ៦៩៨ | ៨៨ ៦៨៤ |
| ជ្រូកពូជ (មេ បា) | ក្បាល | ១ ១៤០ | ៥០៥ | ២០០ | ២០០ | ៧១៧ | ២ ៧៦២ |
| ជ្រូកពូជ (កូន) | ក្បាល | - | ៥ ០០០ | - | - | | ៥ ០០០ |
| ស្វាក្តាម | ក្បាល | ៦ ៩៣៤ | ១០ ៤៧២ | ១៦ ១៩៦ | ២៣ ៧៧០ | ២៣ ២៤៧ | ៨០ ៦១៩ |
| សាច់គោ | តោន | ៧ | ១២ | - | - | - | ១៩ |
| ទឹកដោះគោ | តោន | ៤៥១ | ៧ ៥៥៨ | ៣ ៩៨៤ | - | ៣៨១ | ១២ ៣៧៤ |
| ចំណីឆ្អែ | តោន | ១ ៣៦៥ | ១ ៤៩៤ | ១ ០១១ | ២ ២៧៦ | ៤ ៨៨១ | ១១ ០២៧ |
| រោមសត្វ | តោន | ២៨ | ២៤ | ៨ | ២,៨ | ១២ | ៧៤,៨ |
| ស្បែកគោ-ក្របីសើម | តោន | ១ ៩៧២ | ១ ២៧៥ | ១ ៤៤០ | ១ ៥៥៤ | ១០៤ | ៦ ៣៤៥ |
| ស្បែកគោ-ក្របីស្ងួត | តោន | - | - | - | - | ៩០០ | ៩០០ |
| ស្បែកជ្រូកស្ងួត | តោន | - | - | - | - | ៤៦ | ៤៦ |

## ១.៧.កម្មវិធីកែលម្អពូជ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានផ្សព្វផ្សាយបច្ចេកទេស និងផលប្រយោជន៍នៃការបង្កាត់គោ និងជ្រូកដោយសិប្បនិម្មិតដល់មន្ត្រីជំនាញផលិតកម្ម និងបសុព្យាបាលទាំង២៥រាជធានី ខេត្ត។

នៅឆ្នាំ២០២១ នេះ ការបង្កាត់គោដោយសិប្បនិម្មិតសម្រេចបានចំនួន២ ៦៣២ក្បាល និងមេកើតកូនបានចំនួន១ ១៤២ក្បាល (ញី៦១៩ក្បាល) ស្មើនឹង៤៣% នៃមេដែលបានបង្កាត់សិប្បនិម្មិត និងមេមិនទាន់កើតកូនមានចំនួន ១ ៤៩០ក្បាល ស្មើនឹង៥៧%។ ការបង្កាត់គោដោយសិប្បនិម្មិតនេះបានចូលរួមចំណែកពីវិស័យឯកជនផងដែរ ប៉ុន្តែ

តួលេខនៃការកើតកូនគោមិនស្មើទៅនឹងតួលេខបង្កាត់ពីព្រោះគោដើមមានរយៈពេល០៩ខែ និង១០ថ្ងៃ ដូច្នេះមេគោមួយចំនួនត្រូវកើតកូននៅឆ្នាំបន្ទាប់។ ការបង្កាត់ជ្រូកសិប្បនិម្មិតសម្រេចបានចំនួន១៩ ៤៣៩ក្បាល និងបង្កើតកូនជ្រូកបានចំនួន១៨១ ៤៦៣ក្បាល (ញី៨៤ ១២៥ក្បាល)។ ជាការកត់សម្គាល់ពិនិត្យឃើញថា ពូជជ្រូកត្រូវបានកែលម្អយ៉ាងឆាប់រហ័សនៅទូទាំងប្រទេស (ឧបសម្ព័ន្ធទី៦)។

## ១.៨.អំពីចំណីសត្វ

កម្មវិធីកែលម្អចំណីសត្វ និងផ្សព្វផ្សាយពូជស្មៅ ដែលសំបូរទៅដោយសារធាតុចិញ្ចឹម និងផ្តល់ទិន្នផលខ្ពស់គឺជាសកម្មភាពដ៏អាទិភាពមួយដើម្បីជំរុញផលិតកម្មសត្វ។ បច្ចុប្បន្នការដាំដុះដំណាំចំណីសត្វ បានរីកសាយភាយយ៉ាងទូលំទូលាយនៅទូទាំង២៥រាជធានី ខេត្ត ជាក់ស្តែងក្នុងឆ្នាំ២០២១ នេះ កន្លែងដាំដុះ និងធ្វើបង្ហាញដំណាំចំណីសត្វមានចំនួនសរុប២ ៥៧៩កន្លែង លើផ្ទៃដីចំនួន១ ៨៧៤,៩៥ហិកតា (ឧបសម្ព័ន្ធទី៧)។

ក្នុងឆ្នាំ២០២១ នេះ ក្រុមហ៊ុនដែលបានវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វ នៅក្នុងប្រទេសកម្ពុជាសរុបមានចំនួន២១ក្រុមហ៊ុន រួមមានក្រុមហ៊ុនស៊ីភី, អេហ្វ្រីម៉ាស្ទ័រ, ហ្គ្រីនហ្វីត, បេតាហ្គ្រោ, ញ៉ូវហូប, អ៊ីស្តហូប, ស៊ីជេ, សាណាហ្គ្រូ, អិមភិក អេស៊ីអិមស៊ី, ស៊ីខេវ៉ាយអ៊ី, ប្រាយអេហ្វ្រីស្តារ, វើលដ៍វេត, រោងចក្រចំណីសត្វកណ្តោលជុំ, អេអែនធី ហ្វីដ, ដេហ៊ីស ធីអិមអេច, វឌ្ឍនៈអេនីម៉លហ៊ែល, ហ្វីដប្រូខេអេច, ភីដិបបែលយូអ, នូបលថេស្តហ្វូដ, អាយតាវផេតសិបផ្លាយ និងឡូឌី ផេត ប្រូដាក ដែលមានរោងចក្រផលិតចំណីសត្វសរុបចំនួន២៣រោងចក្រ និងរោងចក្រចំនួន២ទៀតកំពុងដំណើរការសាងសង់បន្ថែម។ ក្នុងឆ្នាំ២០២១ ក្រុមហ៊ុនផលិតចំណីសត្វទាំងអស់ បាននិងកំពុងដំណើរការផលិតចំណីសត្វយ៉ាងសកម្ម ដោយផលិតចំណីសត្វបានប្រមាណជាង១,២៤លានតោន ស្មើនឹងចំនួន៥៥% នៃសមត្ថភាពផលិតរបស់រោងចក្រជាង២,២៧លានតោន (ឧបសម្ព័ន្ធទី៨)។

ម្យ៉ាងទៀត ក្រៅពីចំណីសត្វដែលផលិតបាននៅក្នុងស្រុក ក៏មានក្រុមហ៊ុនមួយចំនួនទៀត បាននាំចូលបន្ថែមនូវចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម ដើម្បីបំពេញសេចក្តីត្រូវការប្រើប្រាស់ និងផលិតចំណីសត្វក្នុងស្រុក។ ជាក់ស្តែងក្នុងឆ្នាំ២០២១ កម្ពុជាបាននាំចូលនូវចំណីសត្វចំនួន៣២២ពាន់តោន វត្ថុធាតុដើមចំនួន៦៧៩ពាន់តោន និងសារធាតុបន្ថែមចំនួន២៩,៨ពាន់តោន បសុឱសថចំនួន៦,៣ពាន់តោន វ៉ាក់សាំងចំនួន១ពាន់តោន សម្ភារបសុពេទ្យ និងឧបករណ៍ចិញ្ចឹមសត្វចំនួន៦៦តោន (ឧបសម្ព័ន្ធទី៩ និងទី១០)។

## ១.៩.ការគ្រប់គ្រងកាកសំណល់សត្វ

ការសាងសង់ឡជីវឧស្ម័ន ត្រូវបានជំរុញ និងលើកទឹកចិត្តឱ្យសាងសង់យ៉ាងទូលំទូលាយ ដើម្បីគ្រប់គ្រងកាកសំណល់សត្វ និងបានទាញយកនូវថាមពលកកើតឡើងវិញ និងផ្តល់នូវជីធម្មជាតិ។

កម្មវិធីឡជីវឧស្ម័នជាតិបានអនុវត្តតាំងពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ននេះ សាងសង់ឡជីវឧស្ម័នគ្រួសារបានចំនួន២៩ ១៨៤ឡ ក្នុងខេត្តចំនួន១៤ គឺខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល ព្រៃវែង ពោធិ៍សាត់ សៀមរាប ស្វាយរៀង តាកែវ ត្បូងឃ្មុំ និងខេត្តបន្ទាយមានជ័យ។ ដោយឡែកក្នុងឆ្នាំ២០២១ កម្មវិធីឡជីវឧស្ម័នជាតិ សាងសង់ឡជីវឧស្ម័នគ្រួសារបានចំនួន៤៩៩ឡ។

គម្រោងសាងសង់ឡជីវឧស្ម័នកម្ពុជា-ចិនចំនួន១ ៥០០ឡ ក្រោមហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន បានអនុវត្តពីចុងឆ្នាំ២០១៩ រហូតមកដល់បច្ចុប្បន្ននេះសាងសង់ឡជីវឧស្ម័នគ្រួសារបានតែចំនួន៥០ឡប៉ុណ្ណោះនៅក្នុងខេត្តចំនួន៧គឺ ខេត្តកំពង់ចាម កំពង់ឆ្នាំង ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង ព្រះវិហារ និងខេត្តត្បូងឃ្មុំ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២១ នេះ ការសាងសង់ឡជីវឧស្ម័នគ្រួសារសម្រេចបានតែចំនួន១០ឡទៀតប៉ុណ្ណោះ (ខេត្តព្រះវិហារ៦ឡ ឧត្តរមានជ័យ២ឡ និងខេត្តពោធិ៍សាត់២ឡ)។ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្ម

សត្វ កំពុងជំរុញ និងកំណត់អត្តសញ្ញាណកសិករដែលស្ម័គ្រចិត្តទទួលឡជីវឧស្ម័នឱ្យបានចំនួនជាក់លាក់ ដើម្បីលើកសំណើសុំថវិកាបដិភាគរបស់រាជរដ្ឋាភិបាលបន្ថែមសម្រាប់អនុវត្តគម្រោងឡជីវឧស្ម័នបន្តទៀត ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។

ម្យ៉ាងទៀត គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន ក្រោមហិរញ្ញប្បទានសម្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០២០ ក្នុងផែនការសាងសង់ឡជីវឧស្ម័នគ្រួសារចំនួន១២ ០០០ឡ នៅខេត្តចំនួន០៤ គឺខេត្តកំពង់ចាម ត្បូងឃ្មុំ តាកែវ និងខេត្តកំពត ពុំទាន់ដំណើរការទេដោយសារបញ្ហាជំងឺកូវីដ-១៩ និងនីតិវិធីលទ្ធកម្ម។







## ២.ការលើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណៈ

សកម្មភាពសំខាន់ៗក្នុងផ្នែកនេះ គឺការពង្រឹងសុខភាពសត្វ អនាម័យសត្វ សាច់ និងផលិតផលសត្វ ដែលផ្តោតសំខាន់លើការត្រួតពិនិត្យអនាម័យ គុណភាព សុវត្ថិភាព ពង្រឹងការផ្តល់សេវាបសុព្យាបាល កាត់បន្ថយការឆ្លងរាលដាលជំងឺសត្វ និងការផ្គត់ផ្គង់សាច់ប្រកបដោយអនាម័យ គុណភាព និងសុវត្ថិភាពនៅលើទីផ្សារ ដើម្បីការពារសុខភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន។

### ២.១.ការលើកកម្ពស់សុខភាពសត្វ

នៅឆ្នាំ២០២១ នេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានពង្រឹងសកម្មភាពត្រួតពិនិត្យ និងទប់ស្កាត់បទល្មើសចរាចរណ៍សត្វ និងការធ្វើអាជីវកម្មសត្វ ដោយបានសហការជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធបានបន្តអនុវត្តសេចក្តីណែនាំអំពីលក្ខខណ្ឌតម្រូវសម្រាប់ការនាំចូល

នាំចេញ និងនាំឆ្លងកាត់សត្វ និងផលិតផលសត្វ។ ជាលទ្ធផលក្នុងរយៈពេលមួយឆ្នាំនេះ នៅទូទាំងប្រទេសបានធ្វើការត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វចំនួនសរុប២០២ករណី ក្នុងនោះអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបានត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វមានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន១១៤ករណី និងបង្ក្រាបបទល្មើសបានចំនួន៥៦ករណី (ដឹកជញ្ជូនមាន់រស់ចំនួន១៨ករណី ជ្រូករស់ចំនួន២៤ករណី សាច់ជ្រូកបង្កកចំនួន០២ករណី សាច់ក្របបង្កកចំនួន០២ករណី ប្រហិតចំនួន០៤ករណី ស្លាបមាន់និងជើងមាន់ចំនួន០២ករណី សាច់គោ ក្របីចំនួន០២ករណី គ្រឿងក្នុងជ្រូកចំនួន០២ករណី) និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តបង្ក្រាបបទល្មើសបានចំនួន៣២ករណី (ដឹកជញ្ជូនមាន់រស់ចំនួន១២ករណី ជ្រូករស់ចំនួន០៧ករណី និងផលិតផលកែច្នៃពីសត្វចំនួន១៣ករណី)។ ជាមួយគ្នានេះដែរ បានធ្វើការអង្កេតតាមដាន បង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺឆ្លងសត្វ ព្រមទាំងបានរៀបចំប្រព័ន្ធព័ត៌មាន និងរាយការណ៍ជំងឺឆ្លងសត្វទាំងថ្នាក់ជាតិ និងអន្តរជាតិ ចាត់វិធានការណ៍ជីវសុវត្ថិភាព និងកម្មវិធីឆ្លើយតបបន្ទាន់ករណីផ្ទុះជំងឺឆ្លងសត្វ។ លទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ២០២១ រួមមានៈ

១.ចាក់វ៉ាក់សាំងការពារជំងឺឆ្លងសំខាន់ៗដែលកើតមានលើគោ ក្របី ពពែ ចៀម ដូចជាជំងឺអុតក្តាម បូសខ្យល់សារទឹក និងជំងឺដុំពកស្បែកគោ ក្របីចំនួនសរុប៩៥០ ៨៨៩ក្បាល ចាក់វ៉ាក់សាំងការពារជំងឺលើជ្រូកចំនួន ២ ២១០ ៦២២ក្បាល ចាក់វ៉ាក់សាំងការពារជំងឺលើបក្សីបានចំនួន៣៨ ៧៧៤ ៤៧១ក្បាល និងចាក់វ៉ាក់សាំងការពារជំងឺលើឆ្កែ និងឆ្មាចំនួន១១ ៧១៣ក្បាល (ឧបសម្ព័ន្ធទី១១ និងទី១២)។

២.ចាត់វិធានការជីវសុវត្ថិភាព ផ្សព្វផ្សាយ និងអនុវត្តផ្ទាល់នៅសត្តឃាតដ្ឋាន ទីផ្សារសត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងចិញ្ចឹមសត្វ មធ្យោបាយដឹកជញ្ជូនសត្វ និងផលិតផលសត្វ និងកន្លែងផ្ទុះជំងឺសត្វសរុបចំនួន ២០២ ០២៤លើក (ឧបសម្ព័ន្ធទី១៣)។

៣.ក្នុងឆ្នាំ២០២១ ភ្នាក់ងារសុខភាពសត្វភូមិទូទាំងប្រទេសមានចំនួន៩ ២៦២ នាក់ ក្នុងនោះស្រី៧២២នាក់ (ឧបសម្ព័ន្ធទី១៤)។

## ២.២.ការពង្រឹងសុខភាពសាធារណៈបសុព្យាបាល

សុខភាពសាធារណៈបសុព្យាបាលជាផ្នែកមួយដ៏សំខាន់ មានភារកិច្ចពង្រឹងការគ្រប់គ្រងបទដ្ឋានបច្ចេកទេសសត្តឃាតដ្ឋាន ស្ថិតិសត្វពិឃាត និងត្រួតពិនិត្យអនាម័យសាច់ សត្វ និងផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន និងកន្លែងកែច្នៃបឋមផលិតផលសត្វ ឱ្យមានលក្ខណៈល្អប្រសើរឡើង ព្រមទាំងធ្វើការវាយតម្លៃផ្តល់គោលការណ៍អនុញ្ញាតបង្កើតសត្តឃាតដ្ឋាន ដើម្បីធានាសុខភាពសាធារណៈតាមរយៈការបង្កើនសមត្ថភាពមន្ត្រីផលិតកម្ម និងបសុព្យាបាលអាជីវករពិឃាតសត្វ និងអ្នកពាក់ព័ន្ធលើការគ្រប់គ្រងសត្តឃាតដ្ឋាន បទដ្ឋានបច្ចេកទេសក្នុងការពិឃាតសត្វ និងសុខុមាលភាពសត្វ ព្រមទាំងអនុវត្តវិធានការបសុព្យាបាល អនាម័យសត្វ សាច់ និងផលិតផលសត្វ។ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានសហការជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ចុះជំរុញការអនុវត្តល្អក្នុងសត្តឃាតដ្ឋានតាមលក្ខណៈបច្ចេកទេស ដោយអនុលោមតាមអនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានយកចិត្តទុកដាក់ខ្ពស់ក្នុងការរៀបចំចងក្រងឯកសារបច្ចេកទេសនានា និងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសពាក់ព័ន្ធនឹងការធ្វើអាជីវកម្មសត្វ ការពិឃាតសត្វតាមបទដ្ឋានបច្ចេកទេសដល់អ្នកពាក់ព័ន្ធ ក្នុងនោះបានចុះណែនាំជំរុញការយល់ដឹងការអនុវត្តល្អក្នុងសត្តឃាតដ្ឋានតាមលក្ខណៈបច្ចេកទេសចំនួន២៥លើក បានបណ្តុះបណ្តាលមន្ត្រីជំនាញ និងអ្នកពាក់ព័ន្ធចំនួន០៣វគ្គ ដែលមានអ្នកចូលរួមចំនួនសរុប៤៦នាក់ ស្ត្រីចំនួន០៨នាក់ និងបានរៀបចំប្រជុំលើកកម្ពស់ការយល់ដឹងអំពីជីវសុវត្ថិភាព និងហេដ្ឋារចនាសម្ព័ន្ធក្នុងសត្តឃាតដ្ឋានចំនួន១០លើក ដែលមានអ្នកចូលរួមចំនួនសរុប១៥០នាក់ ស្ត្រីចំនួន៤៤នាក់។ លើសពីនេះទៅទៀត បានចុះត្រួតពិនិត្យបច្ចេកទេសការស្នើសុំបង្កើតសត្តឃាតដ្ឋានចំនួន១៣កន្លែង (អនុលោមតាមអនុក្រឹត្យលេខ

១០៨) និងបន្តសុពលភាពសត្តឃាដ្ឋានចំនួន១៣កន្លែង (អនុលោមតាមអនុក្រឹត្យលេខ១០៨ចំនួន០៦ និងអនុក្រឹត្យ ១០៨និងវិនិយោគចំនួន០៧) ព្រមទាំងបានចុះជ្រើសរើសសត្តឃាតដ្ឋានគំរូដើម្បីបំពាក់ឧបករណ៍ពិឃាតសត្វតាមស្តង់ដារបច្ចេកទេស និងមានលក្ខខណ្ឌអនាម័យល្អចំនួន០៣កន្លែង រួមមានខេត្តសៀមរាបចំនួន០២កន្លែង និងខេត្តបន្ទាយមានជ័យចំនួន០១កន្លែង។ ដោយឡែកសម្រាប់ឆ្នាំ២០២១ នេះ សត្តឃាតដ្ឋានចំនួន១៦កន្លែង ត្រូវបានកែលម្អស្របតាមស្តង់ដារអនាម័យបច្ចេកទេស។

គិតមកដល់ដំណាច់ឆ្នាំ២០២១ នេះ សត្តឃាតដ្ឋាននៅទូទាំងប្រទេសមានចំនួន២៣៦កន្លែង ក្នុងនោះមានសត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យ១០៨ មានចំនួន១២៣កន្លែង សត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យ១០៨និងវិនិយោគចំនួន៦៣កន្លែង និងសត្តឃាតដ្ឋានវិនិយោគចំនួន៥០កន្លែង ក្នុងនោះមានសត្តឃាតដ្ឋានពិឃាតបក្សីទំនើបនៅខេត្តកណ្តាលចំនួន០១កន្លែង និងសត្តឃាតដ្ឋានពិឃាតគោទំនើបនៅខេត្តតាកែវចំនួន០១កន្លែង។ ទោះបីជាសត្តឃាតដ្ឋានកើនជាលំដាប់ ប៉ុន្តែសត្តឃាតដ្ឋានមួយចំនួននៅមិនទាន់មានអនាម័យល្អស្របតាមបទដ្ឋានបច្ចេកទេសនៅឡើយ។ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានខិតខំណែនាំពង្រឹងការគ្រប់គ្រងអនុវត្តនូវបទដ្ឋានបច្ចេកទេស អនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និងផលិតផលសត្វ និងបង្កើនសមត្ថភាពមន្ត្រីជំនាញផលិតកម្ម និងបសុព្យាបាល ដែលប្រចាំការនៅតាមសត្តឃាតដ្ឋាន និងអ្នកពាក់ព័ន្ធលើការគ្រប់គ្រងសត្តឃាតដ្ឋាន បទដ្ឋានបច្ចេក-ទេសក្នុងការពិឃាតសត្វ និងសុខុមាលភាពសត្វបន្ថែមទៀត (ឧបសម្ព័ន្ធទី១៥ និងទី១៦)។

## ៣.ការផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម

### ៣.១.ការងារផ្សព្វផ្សាយបច្ចេកទេស

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានរៀបចំកម្មវិធីផ្សព្វផ្សាយ សម្ភាសន៍ វេទិកាសាធារណៈ សម្រាប់អ្នកពាក់ព័ន្ធលើប្រធានបទសំខាន់ៗ និងបានផ្សព្វផ្សាយឯកសារបទសម្ភាសន៍ វីដេអូអប់រំបច្ចេកទេសផលិតកម្ម និងបសុព្យាបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ប្រកាស សារាចរ សេចក្តីណែនាំ ព័ត៌មាន និងឯកសារពាក់ព័ន្ធនានា តាមវិទ្យុ ទូរទស្សន៍ គេហទំព័រ ហ្វេសប៊ុក និងចែកជូនការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តទាំង២៥ និងសាធារណៈជននូវឯកសារបង្ហាញពីការចិញ្ចឹមសត្វ និងការដាំដំណាំចំណីសត្វ និងជំងឺឆ្លងសត្វ។ លើសពីនេះទៀត មន្ត្រីជំនាញបានរៀបប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំចំណីសត្វ និងជំងឺឆ្លងសត្វ ជាពិសេសជំងឺប៉េស្តជ្រូកអាហ្វ្រិក ជំងឺផ្តាសាយបក្សី និងជំងឺដុំពកលើស្បែកគោ ក្របី ដល់កសិករចិញ្ចឹមសត្វ និងអ្នកពាក់ព័ន្ធចំនួនសរុប១ ៨០៩នាក់ ស្ត្រីចំនួន៩០៣នាក់។

មន្ត្រីជំនាញបានចុះប្រមូលទិន្នន័យពីក្រុមកសិករចិញ្ចឹមសត្វ សហគមន៍កសិកម្មដែលមានចិញ្ចឹមសត្វ និងសមាគមភ្នាក់ងារសុខភាពសត្វភូមិ រួមជាមួយការចុះវាយតម្លៃដោយផ្ទាល់ជាមួយកសិករសកម្មដែលចិញ្ចឹមសត្វ ក្នុងគោលបំណងដើម្បីរៀបចំសហគមន៍សុខភាពសត្វ និងផលិតកម្មសត្វ។ ឆ្នាំ២០២១ នេះ មន្ត្រីជំនាញបានបន្តរៀបចំប្រជុំជ្រើសរើសថ្នាក់ដឹកនាំ និងរៀបចំលក្ខន្តិកៈសម្រាប់សហគមន៍សុខភាពសត្វ និងផលិតកម្មសត្វ ព្រមទាំងបានចុះផ្សព្វផ្សាយស្តីពីបច្ចេកទេសចិញ្ចឹមសត្វ ដល់សមាជិកក្រុមកសិករចិញ្ចឹមសត្វ សហគមកសិកម្មដែលមានចិញ្ចឹមសត្វ និងសមាគមភ្នាក់ងារសុខភាពសត្វភូមិ រួមមានខេត្តចំនួន០៨ គឺខេត្តកំពង់ធំ សៀមរាប តាកែវ កំពង់ស្ពឺ កំពត កែប ព្រៃវែង និងខេត្តកំពង់ចាម ដោយមានអ្នកចូលរួមចំនួនសរុប៣១៥នាក់ ស្ត្រីចំនួន២០០នាក់។

### ៣.២.ការងារនីតិកម្ម

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបាននឹងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់សំខាន់ៗ ចំនួន១៥ ដែលក្នុងនោះមានលិខិតបទដ្ឋានក្រោមច្បាប់មួយចំនួនត្រូវបានរៀបចំរួចរាល់ និងមួយចំនួនទៀតកំពុងស្ថិតក្នុងដំណើរការរៀបចំ និងបន្តពិភាក្សា។

#### ក.លិខិតបទដ្ឋានគតិយុត្តដែលបានរៀបចំរួចរាល់

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានចូលរួមរៀបចំសេចក្តីណែនាំអន្តរក្រសួងស្តីពីបែបបទនីតិវិធី និងលក្ខខណ្ឌភ្ជាប់នៃការផ្តល់សេវារដ្ឋបាលក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅរដ្ឋបាលរាជធានី ខេត្ត។

## ខ.លិខិតបទដ្ឋានគតិយុត្តដែលកំពុងពិនិត្យ បន្តការរៀបចំ និងពិភាក្សា

១. ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈបសុពេទ្យ។
២. ធ្វើការកែសម្រួលអនុក្រឹត្យលេខ១០៨ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន និងការធ្វើអាជីវកម្មពិឃាតសត្វ។
៣. អនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ។
៤. ធ្វើការកែសម្រួលប្រកាសអន្តរក្រសួងលេខ១០១៣ ស្តីពីសេវាសាធារណៈរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
៥. ប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌។
៦. ប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ។
៧. ប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងការគ្រប់គ្រងសហគមន៍សុខភាពសត្វ និងផលិតកម្មសត្វ។
៨. ប្រកាសស្តីពីនីតិវិធីក្នុងការត្រួតពិនិត្យនូវបសុឱសថ ចំណីសត្វ និងវត្ថុធាតុដើម សារធាតុសកម្ម ឬសារធាតុបន្ថែមដែលនាំចេញ នាំចូល ផលិតលាយផ្សំ និងវេចខ្ចប់ជាថ្មី។
៩. កែសម្រួលប្រកាសស្តីពីនីតិវិធីនៃការជ្រើសរើសការបណ្តុះបណ្តាល ការគ្រប់គ្រងឱ្យមាននិរន្តរភាព និងភារកិច្ចភ្នាក់ងារសុខភាពសត្វភូមិ។
១០.ប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត វិញ្ញាបនបត្របសុព្យាបាល និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ចរាចរណ៍សត្វ និងផលិតផលសត្វ។
១១.ប្រកាសស្តីពីនីតិវិធី និងការតម្រូវសម្រាប់ការទទួលស្គាល់កិច្ចប្រតិបត្តិការរបស់មន្ទីរពិសោធន៍រដ្ឋ និងឯកជនសម្រាប់វិស័យសុខភាពសត្វ និងផលិតកម្មសត្វ។
១២.ប្រកាសស្តីពីនីតិវិធី និងការតម្រូវបទដ្ឋានបច្ចេកទេសសម្រាប់ការបង្កើត ការគ្រប់គ្រង និងការអនុញ្ញាតបង្កើតស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ។
១៣.រៀបចំទម្រង់ពាក្យស្នើសុំ បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់នានាសម្រាប់ការផ្តល់សេវារដ្ឋបាលការងារសុខភាពសត្វ និងផលិតកម្មសត្វ នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលនៅសេសសល់។
១៤.រៀបចំសេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងស្តីពីគោលការណ៍ នីតិវិធី និងស្តង់ដារសេវាសម្រាប់គ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ៣.៣.ការងារចេញលិខិតអនុញ្ញាត និងចុះបញ្ជិកា

ក្រុមហ៊ុនចំណីសត្វចំនួន០៤ បានការអនុញ្ញាតឱ្យផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវចំណីសត្វ ក្នុងនោះមានក្រុមហ៊ុន អេ អេន ធី ហ្វីដ ឯ.ក អាយ តាវ ផេត ស៊ីបផ្លាយ (ខេមបូឌា) ឯ.ក ភី.ដាប់បែលយូ.អ មេនូហ្វេកឈ័ររីង ខមភែនី និងក្រុមហ៊ុនចំរើន ចិត្រា ឯ.ក។ រីឯក្រុមហ៊ុនចំនួន០២ បានការអនុញ្ញាតឱ្យផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវបសុឱសថ រួមមានក្រុមហ៊ុន អឺហ្វាក់ និងក្រុមហ៊ុន វីផាវ៉េត។

ក្រុមហ៊ុនចំណីសត្វចំនួន១៤ក្រុមហ៊ុន បានចុះបញ្ជិកាចំណីសត្វ សារធាតុបន្ថែម និងវត្ថុធាតុដើមចំនួនសរុប ១៨៩មុខ ក្នុងនោះមានចំណីសត្វចំនួន១២០មុខ សារធាតុបន្ថែមចំនួន៦៩មុខ និងបានចុះបញ្ជិកាបសុឱសថ វត្ថុធាតុជីវ-បសុព្យាបាល សារធាតុសកម្ម និងសមាសធាតុចំនួន១៣ក្រុមហ៊ុនចំនួនសរុប៣០០មុខ ក្នុងនោះបសុឱសថចំនួន២៧៨មុខ និងវ៉ាក់សាំងចំនួន២២មុខ។

ក្រុមហ៊ុនចំណីសត្វ បានការអនុញ្ញាតចុះបញ្ជីឃ្លាំងសន្និធិចំនួន១៩ក្រុមហ៊ុន និងបានចុះបញ្ជីឃ្លាំងសន្និធិបសុឱសថចំនួន១១ក្រុមហ៊ុន ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយចំណីសត្វចំនួន២១ក្រុមហ៊ុន ដែលមានយថាប្រភេទចំនួន៧៦៤មុខ និងលិខិតអនុញ្ញាត ផ្គត់ផ្គង់ចែកចាយបសុឱសថចំនួន១១ក្រុមហ៊ុន ដែលមានយថាប្រភេទចំនួន១ ៣០០មុខ។

### ៣.៤.ការងារស្រាវជ្រាវ និងអធិការកិច្ច

ក្នុងឆ្នាំ២០២១ នេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានរៀបចំប្រជុំផ្សព្វផ្សាយច្បាប់ និងកម្រងលិខិតបទដ្ឋានគតិយុត្តវិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងបើកវគ្គបណ្តុះបណ្តាលស្តីពីការអប់រំសមត្ថភាពវិជ្ជាជីវៈអ្នកផ្គត់ផ្គង់ចែកចាយ និងលក់ដុំលក់រាយចំណីសត្វ និងបសុឱសថ ព្រមទាំងនីតិវិធីច្បាប់ និងបទដ្ឋានបច្ចេកទេសសម្រាប់អ្នកលក់ដុំលក់រាយចំណីសត្វ និងបសុឱសថ ដោយមានអ្នកចូលរួមចំនួនសរុប១៨០នាក់ ក្នុងនោះស្រីចំនួន៤៣នាក់។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានចាត់មន្ត្រីចុះធ្វើអធិការកិច្ចប្រកាសប្រតិវេទន៍ចំណីសត្វ និងបសុឱសថនៅតាមក្រុមហ៊ុនចំណីសត្វ និងបសុឱសថក្នុងបណ្តារាជធានី ខេត្តចំនួន៥២ក្រុមហ៊ុន និងធ្វើអធិការកិច្ចតាមដេប៉ូលក់ដុំ លក់រាយចំណីសត្វ និងបសុឱសថក្នុងបណ្តារាជធានី ខេត្ត បានចំនួន៣៣ដេប៉ូ ក្នុងចំណោមដេប៉ូសរុបចំនួន១ ០៦២ដេប៉ូនៅទូទាំង២៥រាជធានី ខេត្ត។ ជាលទ្ធផលមន្ត្រីជំនាញបានរកឃើញនូវចំណុចខ្វះខាតមួយចំនួនដែលមិនទាន់បានអនុវត្តតាមច្បាប់ និងបទដ្ឋានបច្ចេកទេសឱ្យបានត្រឹមត្រូវដូចជា៖ ១).ក្រុមហ៊ុនមួយចំនួននៅបន្តចែកចាយ និងធ្វើចរាចរណ៍ចំណីសត្វ (ជាពិសេសចំណីឆ្កែ ឆ្មា) និងបសុឱសថដែលមិនទាន់បានចុះបញ្ជិកាត្រឹមត្រូវ ២).ក្រុមហ៊ុនមួយចំនួនតូចបានប្រើប្រាស់សំបកវេចខ្ចប់ពុំទាន់ត្រឹមត្រូវតាមការណែនាំ ឬតាមប្រភេទចំណីសត្វ (ក្លែងបន្លំស្លាកសញ្ញាព័ត៌មាន) ៣).បន្តលក់ចំណីសត្វ និងបសុឱសថមិនបានបកប្រែជាភាសាខ្មែរនៅលើសំបកវេចខ្ចប់ចំណី និងបសុឱសថ និង៤).នៅខ្វះចន្លោះក្នុងការអនុវត្តបមាណីយតាមណែនាំរបស់អង្គភាពជំនាញ ដូចមានកំណត់ក្នុងវិញ្ញាបនបត្រ។ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ បានណែនាំ និងធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន និងម្ចាស់ដេប៉ូលក់ដុំ លក់រាយចំណីសត្វ និងបសុឱសថ ដែលនៅខ្វះចន្លោះខាងលើត្រូវអនុវត្តតាមបទដ្ឋានគតិយុត្តដែលបានចូលជាធរមាន។

## ៤.ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ មានសមត្ថភាពធ្វើរោគវិនិច្ឆ័យរកមេរោគបង្កជំងឺឆ្លងសត្វសំខាន់ៗ ភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ ពិនិត្យឈាម សេរ៉ូម កោសិកា/ជាលិកា វះពិនិត្យសាកសពសត្វ វិភាគចំណីសត្វ កាកសំណល់បសុឱសថ និងសារធាតុគីមីនៅក្នុងសត្វ និងផលិតផលសត្វ ផលិតទឹកមេជីវិតគោបង្កកបង្កាត់សិប្បនិម្មិតគោពិសោធន៍ ផលិតថ្នាំសម្លាប់មេរោគ និងបណ្តុះបណ្តាលមន្ត្រីជំនាញលើការងារស្រាវជ្រាវ។

### ៤.១.ការងារស្រាវជ្រាវសុខភាពសត្វ

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ បានធ្វើរោគវិនិច្ឆ័យជំងឺសត្វ តាមដាន អង្កេតឃ្លាំមើល និងស្រាវជ្រាវជំងឺឆ្លងសត្វ និងភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ វិភាគកាកសំណល់បសុឱសថ និងសារធាតុគីមីនៅក្នុងផលិតផលសត្វ។

#### ក.ការងារធ្វើរោគវិនិច្ឆ័យជំងឺសត្វ

បច្ចុប្បន្នវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ មានសមត្ថភាពធ្វើរោគវិនិច្ឆ័យជំងឺគោ ក្របី ជ្រូក បក្សី ឆ្កែ ឆ្មា ស្វា ចៀម ពពែ ដូចជាជំងឺផ្តាសាយបក្សី ញូវកាស ប៉េស្តទា អាសន្នរោគបក្សី ប៉េស្តជ្រូក ប៉េស្តជ្រូកអាហ្វ្រិក ជ្រូកត្រចៀកខៀវ សាល់ម៉ូណែលឡូស៊ីស អឺកូលី កូលីហ្វម ក្លូស្ត្រីឌីយ៉ូម សារទឹក អុតក្តាម បូសខ្យល់

ឈាមខ្មៅ រលូតកូន ផ្តៃឆ្លូត ឡិបតូស្ពីរ៉ូស៊ីស ស៊ីហ្សែលឡា កាំហ្វីឡូបាក់ទែរ រលាកទងសួត ប៊ីវីរុស អេសអរវី ធីអិលវី ជំងឺបណ្តាលមកពីចំណីអាហារ (សាច់ និងផលិតផលសាច់សត្វ ចំណីសត្វ ទឹកដោះគោ ស្បែកគោ ក្របី) និងជំងឺបង្កដោយប៉ារ៉ាស៊ីត។

ឆ្នាំ២០២១ វិទ្យាស្ថានបានយក និងទទួលវត្ថុវិភាគសរុបចំនួន ២២ ១៦៤ មកធ្វើរោគវិនិច្ឆ័យជំងឺ ក្នុងនោះបានរកឃើញវត្តមានមេរោគជំងឺឆ្លងសំខាន់ដូចជា ជំងឺបង្កឡើងដោយវីរុសមានផ្តាសាយបក្សី អុតក្តាម ដុំពកស្បែកគោ ក្របី ប៉េស្តជ្រូកអាហ្វ្រិក ប៉េស្តជ្រូក ជ្រូកត្រចៀកខៀវ និងញ្ញូវកាស ជំងឺបង្កឡើងដោយបាក់តេរីមានសារទឹក បូសខ្យល់គោ ក្របី សាល់ម៉ូណែឡូស៊ីស អ៊ីកូលី ក្លិបស៊ីយែលឡា និងស្តាហ្វីឡូកុកគុស អូរេអ៊ុស និងជំងឺបង្កឡើងដោយប៉ារ៉ាស៊ីតមានកុកស៊ីឌីយ៉ា អេម៉ុងយុស ប៊ុយណូស្តូមូម ស្ត្រុងហ្សីឡូអ៊ីដ កូពេរីយ៉ា តុកសូការ៉ា និងប៉ារ៉ាមហ្វីស្តូមូម។

បន្ថែមពីនេះ វិទ្យាស្ថានបានអង្កេតឃ្លាំមើលវត្តមានជំងឺផ្តាសាយបក្សីនៅទីផ្សារបក្សីរស់ក្នុងរាជធានី ខេត្តចំនួន ១២ (ខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពត កណ្តាល ភ្នំពេញ មណ្ឌលគីរី ព្រៃវែង សៀមរាប ស្វាយរៀង និងខេត្តតាកែវ)។ ជំងឺផ្តាសាយជ្រូក ប៉េស្តជ្រូក ប៉េស្តជ្រូកអាហ្វ្រិក ជ្រូកត្រចៀកខៀវ រលូតកូនជ្រូក ជំងឺគ្រុន Q-Fever និងរលូតកូនគោ នៅតាមសត្តឃាតដ្ឋានក្នុងរាជធានី ខេត្តចំនួន៧ រួមមាន ខេត្តបាត់ដំបង កំពង់ស្ពឺ កណ្តាល ភ្នំពេញ ព្រៃវែង សៀមរាប និងខេត្តតាកែវ។

ឆ្នាំ២០២១ វិទ្យាស្ថានបានវិភាគរកឃើញជំងឺសំខាន់ៗមានដូចជា ជំងឺផ្តាសាយបក្សីផ្ទុះឡើងចំនួន២ករណី គឺ ១).ស្ថិតនៅភូមិព្រៃកតាច្រែង ឃុំព្រៃកនរិទ្ធ ស្រុកឯកភ្នំ ខេត្តបាត់ដំបង និង២).ស្ថិតនៅភូមិទំពស្តេច ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង។ ជំងឺប៉េស្តជ្រូកអាហ្វ្រិកបានរកឃើញតាមរយៈការលួចនាំចូលជ្រូកពីប្រទេសថៃឡង់ដ៍ និងប្រទេសឡាវចំនួន៥ករណី ក្នុងនោះ៤ករណីនាំចូលពីប្រទេសថៃឡង់ដ៍គឺ ១).ឃាត់ចាប់បានក្នុងខេត្តបន្ទាយមានជ័យចំនួន២ករណី រាជធានីភ្នំពេញចំនួន២ករណី និង១ករណីនាំចូលពីប្រទេសឡាវតាមខេត្តស្ទឹងត្រែង។ ជំងឺដុំពកស្បែកគោ ក្របី បានរកឃើញរាយប៉ាយនៅទូទាំង២៥ រាជធានី ខេត្ត ចាប់ពីខែមិថុនា រហូតដល់ខែវិច្ឆិកា ឆ្នាំ២០២១ ប៉ុន្តែក្រោយពីមន្ត្រីជំនាញចុះអន្តរាគមន៍ពិនិត្យព្យាបាល ចាក់វ៉ាក់សាំង យកវត្ថុវិភាគ អនុវត្តវិធានជីវសុវត្ថិភាព អប់រំណែនាំ និងផ្សព្វផ្សាយបច្ចេកទេសដល់កសិករចិញ្ចឹមសត្វបានធ្វើឱ្យជំងឺមានសភាពស្ងប់ស្ងាត់ទៅវិញ។

### ខ.តាមដានភាពស៊ាំបសុឱសថប្រឆាំងនឹងមេរោគ

ការប្រើប្រាស់អង់ទីប៊ីយ៉ូទិកនៅក្នុងការចិញ្ចឹមសត្វនៅកម្ពុជាអាចនាំទៅរកភាពស៊ាំទៅនឹងឱសថ ដោយសារមិនមានការគ្រប់គ្រងច្បាស់លាស់។ ឆ្លើយតបទៅនឹងបញ្ហានេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបាននឹងកំពុងធ្វើការអង្កេតតាមដានអំពីស្ថានភាពនៃភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគនៅកម្ពុជាជាប្រចាំ។ ក្នុងឆ្នាំ២០២១ វិទ្យាស្ថានបានយកវត្ថុវិភាគតំបារចំនួន២២៤ ពីទីផ្សារលក់មាន់នៅខេត្តកំពង់ស្ពឺ តាកែវ និងរាជធានីភ្នំពេញ ដែលជាលទ្ធផលមានវត្តមានអ៊ីកូលី ៦៣ (២៨%) សាល់ម៉ូណែលឡា ២ (១%) និងក្លិបស៊ីយែលឡា ១៣ (៦%)។ បាក់តេរីទាំងនេះមានភាពស៊ាំទៅនឹងអង់ទីប៊ីយ៉ូទិកជាច្រើនប្រភេទ។

### គ.វិភាគកាកសំណល់បសុឱសថ និងសារធាតុគីមីនៅក្នុងផលិតផលសត្វ

សមត្ថភាពមន្ត្រីលើការវិភាគគុណភាពបសុឱសថ និងកាកសំណល់បសុឱសថ បានពង្រឹង តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលលើការប្រើប្រាស់ឧបករណ៍ UPLC-MS MS និង CHARM II លើការវិភាគកាកសំណល់បសុឱសថ និងសារធាតុគីមីនៅក្នុងផលិតផលសត្វ។ វិទ្យាស្ថានបានយក និងទទួលវត្ថុវិភាគចំនួន២៥៦វត្ថុវិភាគក្នុងនោះចំនួន២២០វត្ថុវិភាគ មានសាច់គោចំនួន៦០ សាច់ជ្រូកចំនួន៩០ និងសាច់មាន់ចំនួន៧០ ពីទីផ្សារនៅខេត្តកំពង់ចាម កំពង់ស្ពឺ ព្រះសីហនុ ព្រៃវែង ស្វាយរៀង តាកែវ និងខេត្តត្បូងឃ្មុំ និងទទួលវត្ថុវិភាគសាច់ និងផលិតផលសត្វចំនួន៣៦វត្ថុវិភាគ មានសាច់គោបង្កកចំនួន៧ ក្រួចបង្កកចំនួន១៤ សាច់ជ្រូកចំនួន៣ គ្រឿងក្នុងជ្រូកនិងមាន់ចំនួន១២ មកពីប្រទេសវៀតណាម ដើម្បីវិភាគរកកាកសំណល់អង់ទីប៊ីយ៉ូទិកក្នុងក្រុមតេត្រាស៊ីគ្លីន ស៊ុលហ្វា បេតាអាហ្គោនីស និង

សារធាតុហ្សរម៉ុល។ លទ្ធផលនៃការវិភាគបង្ហាញថា មិនមានវត្តមានសំណល់អង់ទីប៊ីយ៉ូទិកក្នុងក្រុមតេត្រាស៊ីគ្លីន ស៊ុលហ្វាបេតាអាហ្គោនីស និងហ្សរម៉ុលនៅក្នុងផលិតផលទាំងនោះទេ។

វិទ្យាស្ថាន បានសហការជាមួយអ្នកជំនាញជនជាតិរុស្ស៊ីធ្វើការពិសោធន៍ និងផលិតថ្នាំសម្លាប់មេរោគដោយប្រើបច្ចេកទេសអេឡិកត្រូលីត្រទឹក ដែលមានលទ្ធភាព និងប្រសិទ្ធភាពក្នុងការសម្លាប់មេរោគបានយ៉ាងល្អ។ ទឹកថ្នាំសម្លាប់មេរោគនេះ ត្រូវបានប្រើប្រាស់ក្នុងការសម្លាប់មេរោគនៅក្នុងមន្ទីរពិសោធន៍នានារបស់វិទ្យាស្ថាន។

## ៤.២.ការងារស្រាវជ្រាវផលិតកម្មសត្វ

### ក.សេនេទិក និងការបង្កាត់ពូជសត្វ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វមានស្ថានីយពិសោធន៍ស្រាវជ្រាវចំនួនមួយកន្លែងសម្រាប់ធ្វើការពិសោធន៍ស្រាវជ្រាវពូជសត្វគឺ ស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅដែលមានគោសរុបចំនួន១១១ក្បាល។ វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ បានសហការសិក្សាស្រាវជ្រាវពូជសត្វល្អៗដែលមានស្រាប់ក្នុងស្រុកក្នុងការផលិតទឹកមេជីវិត ពិនិត្យគុណភាព ធ្វើការបង្កក បង្កាត់សិប្បនិម្មិត ដើម្បីកាត់បន្ថយការនាំចូលទឹកមេជីវិតបង្កកពីបរទេស។ នៅឆ្នាំ២០២១នេះ វិទ្យាស្ថានបានផលិត និងចែកចាយទឹកនីត្រូសែនចំនួន១ ៨០៥លីត្រទៅតាមបណ្ដាខេត្តនានា និងទឹកមេជីវិតគោបង្កកចំនួន១ ២១០ដើម ក្នុងនោះ៨៧០ដើមបានបែងចែកជូនខេត្តកំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ពោធិ៍សាត់ ព្រៃវែង សៀមរាប ស្ទឹងត្រែង តាកែវ និងរាជបណ្ឌិតសភាកម្ពុជា។ នៅឆ្នាំ២០២១ បង្កាត់សិប្បនិម្មិតគោពិសោធន៍បានចំនួន៦៤០ក្បាល និងកើតកូនបានចំនួន២១៨ក្បាល។

ឆ្នាំ២០២១ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វដឹកនាំចុះបង្កាត់គោដោយសិប្បនិម្មិតនៅឃុំកោះរកា កោះទន្ទឹម និងឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាមចំនួន២១៤ក្បាល កើតកូនបានចំនួន២១ក្បាល នៅសល់មេដើមមិនទាន់គ្រប់ខែកើតកូនចំនួន៩៣ក្បាល។

**តារាងលទ្ធផលនៃការផលិត និងចែកទឹកមេជីវិតបង្កកគោ និងទឹកនីត្រូសែនពីឆ្នាំ២០១៨-២០២១**

| សកម្មភាព | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ |
|---|---|---|---|---|
| ផលិតទឹកមេជីវិតគោបង្កក (ដើម) | ១ ៥៥០ | ១ ៥១០ | ២ ៥០០ | ១ ២១០ |
| បែងចែកទឹកមេជីវិតគោបង្កក(ដើម) | ៣ ៤៨០ | ៦០០ | ៩៨០ | ៨៧០ |
| បង្កាត់គោដោយសិប្បនិម្មិត (ក្បាល) | ៨៣៨ | ៨៤០ | ២ ៣៥៧ | ៦៤០ |
| បែងចែកទឹកនីត្រូសែន (លីត្រ) | - | ៣៩០ | ១ ០២៥ | ១ ៨០៥ |

នៅឆ្នាំ២០១៨ ដោយមានការគាំទ្រពីកម្មវិធី EU-PGA-L និងគម្រោង IAEA អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបានធ្វើការបែងចែកទឹកមេជីវិតគោបង្កកដល់ការិយាល័យផលិតកម្ម និងបសុព្យាបាលមានចំនួនច្រើន។ ប៉ុន្តែនៅឆ្នាំ២០១៩ ដោយបរិមាណទឹកមេជីវិតដែលបានចែកជូនប្រើមិនទាន់អស់ ទើបការស្នើសុំ និងចែកជូនមានចំនួនថយចុះ។

### ខ.ការវិភាគចំណីសត្វ

វិទ្យាស្ថាន បានវិភាគគុណភាពចំណីសត្វដោយពិនិត្យទៅលើប៉ារ៉ាម៉ែតសំខាន់ៗមួយចំនួនដូចជា ប្រូតេអ៊ីន ខ្លាញ់ ផូស្វ័រ សារធាតុសរសៃ សំណើម ផេះ ជាតិម្សៅ និងវត្ថុធាតុដើមផ្សំចំណីសត្វក្នុងនោះចំណីមាន់ (សាច់ ពង និងកូន) ចំណីជ្រូក (សាច់ មេដើម មេបំបៅ បា និងកូន) ចំណីទា (ពង សាច់ និងកូន) មេចំណី ចំណីគោ ចំណីត្រី ចំណីផ្លែ ឆ្មា និងកាកស្វាយ ដើម្បីធានាថាចំណីសត្វដែលដាក់លក់នៅលើទីផ្សារពិតជាមានគុណភាពល្អ។

## ៥.ការពង្រឹងការផ្តល់សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ

### ៥.១.ការពង្រឹងការគ្រប់គ្រងអង្គភាព

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងការតែងតាំង ផ្ទេរ និងប្រគល់ភារកិច្ចថ្នាក់ដឹកនាំជាមួយនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន វិទ្យាស្ថាន ការិយាល័យ មន្ទីរពិសោធន៍ និងស្ថានីយស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល ស្របតាមតាមអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងប្រកាសលេខ៣៨១ ប្រក.កសក.ប ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វស្របតាមការតែងតាំងរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

នៅទូទាំងប្រទេសមន្ត្រីបម្រើការងារសុខភាពសត្វ និងផលិតកម្មសត្វចំនួនសរុប៧៧០រូប ស្រីចំនួន១៧២រូប ក្នុងនោះមន្ត្រីបម្រើការងារនៅថ្នាក់កណ្តាលចំនួនសរុប២៩៤រូប ស្រីចំនួន៨៨រូប និងមន្ត្រីបម្រើការងារនៅទូទាំង២៥ រាជធានី ខេត្ត ចំនួនសរុប៤៧៦រូប ស្រីចំនួន៨៤រូប (ឧបសម្ព័ន្ធទី១៧)។

### ៥.២.ការអភិវឌ្ឍធនធានមនុស្ស

ឆ្លើយតបទៅនឹងការកំណត់អាទិភាពនៃកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានយកចិត្តទុកដាក់លើការបង្កើនសមត្ថភាពមន្ត្រីជាបន្តបន្ទាប់ ទាំងសមត្ថភាពរៀបចំ និងអនុវត្តផែនការ ព្រមទាំងសមត្ថភាពបច្ចេកទេសសម្រាប់ផ្តល់សេវាសុខភាពសត្វ និងផលិតកម្មសត្វឱ្យកាន់តែប្រសើរថែមទៀតដោយបានគៀរគរជំនួយពីដៃគូអភិវឌ្ឍន៍ និងគាំទ្រនានាពីរាជរដ្ឋាភិបាលសម្រាប់បង្កើនសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធ ផ្តោតលើអាទិភាពនៃការសិក្សាពីតម្រូវការបណ្តុះបណ្តាលលើការងារគ្រប់គ្រង និងបច្ចេកទេសដោយសម្របសម្រួលចាត់មន្ត្រីបច្ចេកទេសចូលរួមប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា ដែលរៀបចំដោយរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍ដោយផ្ទាល់ និងតាមរយៈប្រព័ន្ធវីដេអូពីចម្ងាយចំនួន២៨លើក ក្នុងនោះអ្នកចូលរួមចំនួន៣០៥នាក់ ស្រី៦៣នាក់។

### ៥.៣.ការងាររៀបចំផែនការ

ឆ្នាំ២០២១ នេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រនានា ផែនការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម កសាងផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ សម្រាប់ត្រៀមរៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព និងទិសដៅការងារសម្រាប់អនុវត្តបន្តដោយធ្វើបច្ចុប្បន្នភាពលើផែនការ និងកម្មវិធីសម្រាប់ទិសដៅសំខាន់ៗដូចខាងក្រោម៖

១.ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣។

២.ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤។

៣.ផែនការសកម្មភាពឆ្នាំ២០២២ សម្រាប់ថវិកាកម្មវិធីរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

៤.កម្មវិធីវិនិយោគសាធារណៈ០៣ឆ្នាំរំកិល ២០២២-២០២៤។

លើសពីនេះទៀត អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបានផ្តល់ធាតុចូលលើទស្សនទានសម្រាប់គម្រោងក្នុងការនាំចេញផលិតផលកសិកម្មហេដ្ឋារចនាសម្ព័ន្ធ និងការស្រាវជ្រាវទាក់ទងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ សេចក្តីព្រាងក្របខណ្ឌយុទ្ធសាស្ត្រកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី២០២១-២០២៣ ឯកសារគោលដៅអភិវឌ្ឍន៍ដោយចិរភាពកម្ពុជា២០១៦-២០៣០ ក្របខ័ណ្ឌជំរុញវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មកម្ពុជា២០២១-២០២២ និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា២០១៩-២០២៣។

## ៥.៤.ការពង្រឹងសេវាសុខភាពសត្វ និងផលិតកម្មសត្វ

សេវាសំខាន់ៗ ដែលអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បាននឹងកំពុងអនុវត្តរួមមានការត្រួតពិនិត្យ ចេញលិខិតអនុញ្ញាត និងចេញវិញ្ញាបនបត្រមានដូចជា នាំចូល នាំចេញ និងនាំឆ្លងកាត់សត្វនិងផលិតផលសត្វ បង្កើតសត្តឃាតដ្ឋាន កសិដ្ឋានចិញ្ចឹមសត្វនិងបង្កាត់ពូជសត្វ ផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មី ផ្គត់ផ្គង់ចែកចាយ ចុះបញ្ជី បញ្ជីឃ្លាំងសន្និធិនិងការវិភាគចំណីសត្វ វត្ថុធាតុដើម សារធាតុបន្ថែម បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្មសមាសធាតុគ្រប់ប្រភេទ និងការវិភាគគុណភាពសត្វ សាច់ និងផលិតផលសត្វ ព្រមទាំងបង្ក្រាបបទល្មើសចរាចរណ៍សត្វ និងផលិតផលសត្វ។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ស្ថិតនៅក្នុងកម្មវិធីទី២ លើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ មានអនុកម្មវិធីចំនួន០៣ យោងតាមច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វមានថវិកាចំនួន១៣ ១៥២ ១០០ ០០០រៀល។ ក្រោយពីវិចារណកម្មអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វនៅថវិកាចំនួន១១ ២៤៣ ០០០ ០០០រៀល អនុវត្តបាន៨៨,៣៣% ។

ក្នុងការបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តទាំង២៥ នៅឆ្នាំ២០២១ បានប្រមូលចំណូលចំនួនសរុប ១២ ៧៨៩ ៣០៧ ៨២៥រៀល ក្នុងនោះចំណូលបានមកពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វមានចំនួន ៨ ៧២៧ ០៩០ ៤៧៥រៀល និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តចំនួន៤ ០៦២ ២១៧ ៣៥០រៀល។ បើប្រៀបធៀបនឹងឆ្នាំ២០១៧ មានកំណើនចំនួន៦៨,៤៥% និងធៀបនឹងឆ្នាំ២០២០ ថយចុះចំនួន(-២៨,៥៣%) ដែលក្នុងនោះថ្នាក់កណ្តាលថយចុះចំនួន(-៣៧%) និងរាជធានី ខេត្តកើនចំនួន០,៥១%។ ការថយចុះចំណូលបណ្តាលមកពីផលិតកម្មសត្វក្នុងស្រុកមានសន្ទុះកើនឡើងខ្ពស់ ជាពិសេសជាក់ស្តែងចាប់ខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២១ មិនមានករណីជ្រូកសាច់រស់ ជ្រូកមេ បាពូជ និងកូនជ្រូកពូជនាំចូលពីបរទេសឡើយ ប៉ុន្តែបើប្រៀបធៀបនឹងច្បាប់ថវិកាឆ្នាំ២០២១ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វរកចំណូលបានប្រមាណ១៧៩,៣ភាគរយ។ ម្យ៉ាងវិញទៀត កម្ពុជាទទួលរងនូវជំងឺផ្លូវដង្ហើមប្រភេទថ្មី (COVID-19) ធ្វើឱ្យកម្មវិធីតាមបែបប្រពៃណីស្ទើរតែទាំងអស់ត្រូវបានផ្អាក (ពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យ...) បណ្តាលឱ្យការបរិភោគសាច់សត្វថយចុះ។

### ក្រាហ្វិកប្រៀបធៀបលទ្ធផលប្រមូលពីឆ្នាំ២០១៧-២០២១



### ៥.៥.ការងារសហប្រតិបត្តិការ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអង្គការអន្តរជាតិ ដែលរួមមាន៖ OIE, FAO, ASEAN, CHINA, KOICA, ACIAR, IAEA, JICA, UNIDO, WB, ADB, DTRA, USAID។

#### ក.កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍

អង្គការសុខភាពសត្វពិភពលោក (OIE) អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ (FAO) និងប្រទេសអាស៊ាន ដៃគូអភិវឌ្ឍន៍ដូចជា សាធារណៈរដ្ឋប្រជាមានិតចិន ACIAR, IAEA, KOICA បានត្រូវពង្រឹង និងពង្រីកស្របតាមអភិក្រមភាពជាម្ចាស់ និងបម្រើឱ្យកម្មវិធីអភិវឌ្ឍន៍នៃអនុវិស័យ។

#### ខ.កិច្ចសហការជាតិ អង្គការសង្គមស៊ីវិល និងវិស័យឯកជន

បច្ចុប្បន្ននេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សហការជាមួយសមាគមអ្នកចិញ្ចឹមសត្វកម្ពុជា និងក្រុមហ៊ុនទាក់ទងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

#### គ.កម្មវិធី និងគម្រោងសំខាន់ៗកំពុងអនុវត្ត

កម្មវិធី និងគម្រោងគាំទ្រការអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ រួមមាន៖ ថវិកាតាមកម្មវិធីរបស់រាជរដ្ឋាភិបាល កម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ (NBP) គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាគរបរិស្ថាន និងកម្មវិធីឡជីវឧស្ម័នពីរដ្ឋាភិបាលចិន គម្រោងពិពិធកម្មវិស័យកសិកម្មកម្ពុជា គម្រោងពង្រឹងសមត្ថភាពចំណីអាហារ និងចំណីសត្វថ្នាក់ជាតិ គម្រោងគាំទ្របច្ចេកទេសដើម្បីអភិវឌ្ឍ និងអនុវត្តប្រព័ន្ធអត្តសញ្ញាណកម្មនិងចុះបញ្ជីសត្វ គម្រោង Understanding the Risk of Zoonotic Disease from Swine Production and Exchange Systems in Cambodia។

## V.កាលានុវត្តភាព និងបញ្ហាប្រឈម

កម្ពុជាមានសក្តានុពលអភិវឌ្ឍផលិតកម្មសត្វផ្អែកលើទីតាំងភូមិសាស្ត្រជាយុទ្ធសាស្ត្រនៅក្នុងអាស៊ាន និងអនុ-តំបន់ទន្លេមេគង្គ មានផ្ទៃដីកសិកម្មធំទូលាយមិនទាន់ប្រើប្រាស់អស់សក្តានុពល ដែលផ្តល់លក្ខខណ្ឌសមស្របក្នុងការចិញ្ចឹមសត្វ និងដាំដំណាំចំណីសត្វ។ ការកើនឡើងចំនួនប្រជាជនជារៀងរាល់ឆ្នាំ បានធ្វើឱ្យមានកំណើនតម្រូវការសាច់ក្នុងស្រុកទាមទារឱ្យមានការបង្កើនផលិតកម្មសត្វ ការស្រាវជ្រាវសុខភាពសត្វនិងផលិតកម្មសត្វ ការកែច្នៃផលិតផលសត្វ និងចំណីសត្វនិងដំណាំចំណីសត្វ។ ប៉ុន្តែជាមួយនឹងកាលានុវត្តភាពខាងលើទាំងនេះ ការអភិវឌ្ឍន៍អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វជួបនូវបញ្ហាប្រឈមមួយចំនួន ដោយសារកត្តាផ្សេងទៀតមានជាអាទិ៍ ១).ភាពយឺតយ៉ាវនៃការប្តូរតវិយាបទពីផលិតកម្មសត្វតាមបែបប្រពៃណីទៅជាផលិតកម្មសត្វតាមបែបពាណិជ្ជកម្ម ២).បរិយាកាសសម្រាប់ការរីកលូតលាស់នៃពាណិជ្ជកម្មសត្វនៅមានកម្រិត ជាពិសេសពាក់ព័ន្ធនឹងធាតុចូលសំខាន់ៗដូចជា តម្លៃអគ្គិសនីខ្ពស់ វត្ថុធាតុដើមមួយចំនួន និងថ្នាំការពារព្យាបាលសត្វមិនអាចផលិតក្នុងស្រុកបានដែលតម្រូវឱ្យមានការនាំចូល ឡជីស្ទិកធ្វើឱ្យចំណីសត្វមានតម្លៃខ្ពស់ វាលស្មៅធម្មជាតិកាន់តែធ្លាក់ចុះ ខ្វះកម្លាំងពលកម្ម សត្វ និងផលិតផលសត្វមិនទាន់ស្របតាមស្តង់ដារទីផ្សារតម្រូវនិងភាពខ្វះចន្លោះព័ត៌មានទីផ្សារ បទដ្ឋានគតិយុត្តមិនទាន់គ្រប់ជ្រុងជ្រោយដើម្បីសម្រួលពាណិជ្ជកម្មសត្វ ៣).ជំងឺស៊ូល្ហូស (ផ្តាសាយបក្សី) និងជំងឺឆ្លងរាលដាលសត្វ (ប៉េស្តជ្រូកអាហ្វ្រិក ដុំពកស្បែកគោ ក្របី) ៤). ឧបករណ៍សម្ភារបម្រើការស្រាវជ្រាវនៅមន្ទីរពិសោធន៍មិនគ្រប់គ្រាន់តាមតម្រូវការ ៥).ប្រព័ន្ធគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យនៅមានកម្រិត និង៦).ធនធានមនុស្សមិនទាន់គ្រប់គ្រាន់តាមតម្រូវការ និងសមត្ថភាពជំនាញនៅមានកម្រិត ៧).បញ្ហាជំងឺកូវីដ-១៩ កម្មវិធីតាមបែបប្រពៃណីខ្លះត្រូវបានផ្អាក (ពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យ...) ធ្វើឱ្យការបរិភោគសាច់សត្វថយចុះ និងម្យ៉ាងទៀតពេលខ្លះធ្វើឱ្យប្រភេទសាច់សត្វមួយចំនួនមានតម្លៃខ្ពស់ និងពេលខ្លះក៏តម្លៃធ្លាក់ចុះផងដែរ។

## VI. ទិសដៅអនុវត្តឆ្នាំ២០២២

### ១.សូចនាករទិសដៅ

ការកំណត់ទិសដៅបន្ត២០២២ របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ ដូចខាងក្រោម៖

- ផលិតផលសាច់សរុបកើន៣%ក្នុងមួយឆ្នាំ គឺពី២៤០ពាន់តោននៅឆ្នាំ២០១៩ ដល់២៧០ពាន់តោននៅឆ្នាំ២០២៣
- អត្រានៃការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យកើនគឺ ពី២៣% នៅឆ្នាំ២០១៩ ដល់៣០% នៅឆ្នាំ២០២៣។ ជាក់ស្តែងក្នុងឆ្នាំ២០២១នេះ អត្រាចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មកើនដល់២៣,៦% ដូច្នេះបញ្ជាក់ឱ្យឃើញថា អ្នកចិញ្ចឹមសត្វមានការយល់ដឹងច្រើនបានកែប្រែពីការចិញ្ចឹមបែបលក្ខណៈគ្រួសារ (យថាផល) មកជាការចិញ្ចឹមតាមលក្ខណៈបច្ចេកទេសក្នុងរូបភាពបែបលក្ខណៈពាណិជ្ជកម្ម
- កាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅក្រោម៥%។

### ២.វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

#### ២.១.បង្កើនផលិតកម្មសត្វ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ បានកំណត់ទិសដៅបង្កើនផលិតផលសាច់ឱ្យបានដល់ចំនួន២៦២ពាន់តោន និងបង្កើនការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យកើនដល់ចំនួន២៩% នៅឆ្នាំ២០២២។ ប៉ុន្តែការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មក្នុងឆ្នាំ២០២១នេះកើនដល់ចំនួន៣៩% បើធៀបសូចនាករឆ្នាំ២០២២ បានកើនលើសផែនការ ហើយអាចបន្តកើនឡើងបន្ថែមទៀត។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នឹងបន្តផ្តល់សេវាបសុព្យាបាល និងបង្កើនសមត្ថភាពបច្ចេកទេសដល់កសិករចិញ្ចឹមសត្វ តាមរយៈកម្មវិធីចាក់វ៉ាក់សាំងការពារ ពិនិត្យព្យាបាលជំងឺសត្វ អនុវត្តវិធានជីវ-សុវត្ថិភាព បណ្តុះបណ្តាលបច្ចេកទេស និងអនុវត្តការចិញ្ចឹមសត្វល្អ ជាពិសេសជំរុញផ្លាស់ប្តូរឥរិយាបទពីការចិញ្ចឹមតាមបែបប្រពៃណីទៅជាការចិញ្ចឹមបែបទំនើបសម្រាប់ធ្វើពាណិជ្ជកម្ម ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារនាពេលបច្ចុប្បន្ន តាមរយៈការកែលម្អពូជ ចំណីមានគុណភាពល្អ និងកាត់បន្ថយជំងឺឆ្លងរាលដាលសត្វ។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានផ្តល់ការគាំទ្រធ្វើឱ្យប្រសើរនូវបរិយាកាសវិនិយោគលើការចិញ្ចឹមសត្វ និងផលិតចំណីសត្វ ដើម្បីធ្វើឱ្យថ្លៃដើមផលិតកម្មសត្វទាបដោយការកែច្នៃវត្ថុធាតុដើមក្នុងស្រុកដែលមានស្រាប់។

#### ២.២.បង្កើនសុខភាពសាធារណៈបសុព្យាបាល

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ បានកំណត់កែលម្អសត្តឃាតដ្ឋានតាមបទដ្ឋានបច្ចេកទេសឱ្យបានចំនួន៥៩កន្លែងនៅឆ្នាំ២០២២។ ដើម្បីសម្រេចបានតាមទិសដៅខាងលើអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វបន្តពង្រឹងការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ ពង្រឹងអនុវត្តច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី និងបណ្តុះបណ្តាលពីបច្ចេកទេសពិឃាតសត្វប្រកបដោយមនុស្សធម៌ដល់ម្ចាស់សត្តឃាតដ្ឋាន និងអាជីវករពិឃាតសត្វ។

#### ២.៣.បង្កើនប្រសិទ្ធភាពអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បន្តជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំនានា ពង្រឹងសមត្ថភាពមន្ត្រីនិងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ បង្កើនការត្រួតពិនិត្យនិងធ្វើអធិការកិច្ចលើអាជីវកម្មនាំចូល នាំចេញ និងនាំឆ្លងកាត់សត្វនិងផលិតផលសត្វ សត្តឃាតដ្ឋាន កសិដ្ឋានចិញ្ចឹមសត្វនិងបង្កាត់ពូជសត្វ កន្លែង

ផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មី កន្លែងផ្គត់ផ្គង់ចែកចាយ ឃ្លាំងសន្និធិចំណីសត្វ វត្ថុធាតុដើម សារធាតុបន្ថែម បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម សមាសធាតុគ្រប់ប្រភេទ ដើម្បីបង្ការ ទប់ស្កាត់ការឆ្លងរាលដាលជំងឺសត្វ ការពារសុខភាពសត្វ សុខភាពសាធារណៈ សុខុមាលភាពសត្វ និងបរិស្ថាន។

### ២.៤.បង្កើនសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធ

ការបង្កើនសមត្ថភាពមន្ត្រីគ្រប់កម្រិត ដើម្បីផ្ទេរចំណេះដឹងលើជំនាញសុខភាពសត្វ និងផលិតកម្មសត្វដូចជា ការចិញ្ចឹម ការបង្កាត់ពូជសត្វ សុវត្ថិភាពចំណីអាហារ បសុឱសថ ជីវសុវត្ថិភាព ការបង្ការជំងឺឆ្លងរាលដាលសត្វ ខ្សែច្រវាក់ផលិតកម្មសត្វ ការធ្វើពាណិជ្ជកម្មសត្វដល់វិស័យឯកជន អង្គការដៃគូអភិវឌ្ឍន៍ សហគមន៍ សមាគម កសិករចិញ្ចឹមសត្វ ដើម្បីបង្កើនផលិតភាពសត្វ។ លើសពីនេះទៀត ភ្នាក់ងារសុខភាពសត្វត្រូវបានបណ្តុះបណ្តាលពីជំនាញបច្ចេកទេស សុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីសម្របសម្រួល ជួយពិនិត្យព្យាបាលសត្វ និងផ្តល់ព័ត៌មានពីស្ថានភាពជំងឺសត្វ ដល់មន្ត្រីជំនាញបានទាន់ពេល។

### ២.៥.ចងក្រងសហគមន៍អ្នកចិញ្ចឹមសត្វ និងផលិតកម្មតាមកិច្ចសន្យា

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ជំរុញលើកទឹកចិត្តសហគមន៍ចិញ្ចឹមសត្វ កសិករចិញ្ចឹមសត្វ តាមកិច្ចសន្យា ដើម្បីលើកកម្ពស់ផលិតកម្មសត្វ ធានាបាននូវបរិមាណផ្គត់ផ្គង់ ការពារផលប្រយោជន៍នូវផលិតផល ដែលផលិតបាន ក្នុងការកាត់បន្ថយការនាំចូលសត្វពីបរទេស និងឈានទៅរកការនាំចេញ។

### ២.៦.ពង្រឹងការស្រាវជ្រាវ និងផ្សព្វផ្សាយ

វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ បន្តពង្រឹងការសិក្សាស្រាវជ្រាវ ការអង្កេតតាមដាន ជំងឺឆ្លងសត្វ សំដៅរកឱ្យឃើញប្រភពជំងឺ និងឆ្លើយតបទាន់ពេលវេលា ព្រមទាំងពង្រឹងការស្រាវជ្រាវចំណីសត្វ បសុឱសថ ពូជសត្វដែលមានលក្ខណៈបន្សាំនឹងការប្រែប្រួលអាកាសធាតុ ធន់នឹងជំងឺ លូតលាស់លឿន និងស្របនឹងតម្រូវការ ទីផ្សារ និងការបង្កាត់ពូជសិប្បនិម្មិត រួមជាមួយនឹងការបង្កើនសមត្ថភាពមន្ទីរពិសោធន៍ សមត្ថភាពស្រាវជ្រាវ និង បង្កើនធនធាន (មនុស្ស សម្ភារ និងថវិកា) សម្រាប់ការស្រាវជ្រាវ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ។

### ២.៧.លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ តែងតែមានកិច្ចពិភាក្សាពិគ្រោះយោបល់ ចែករំលែកព័ត៌មាន ជាមួយវិស័យឯកជន អង្គការសង្គមស៊ីវិល សហគមន៍ សមាគម និងកសិករចិញ្ចឹមសត្វពាក់ព័ន្ធនឹងការងារសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីដោះស្រាយបញ្ហាប្រឈមកើតមានឡើងលើការចិញ្ចឹមសត្វ តម្លៃទីផ្សារ ស្ថានភាពជំងឺឆ្លងសត្វ និងការចរាចរណ៍សត្វនិងផលិតផលសត្វ។

### ២.៨.បង្កបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការវិនិយោគ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ លើកទឹកចិត្ត គាំទ្រ និងជួយសម្របសម្រួលជាមួយក្រសួង ពាក់ព័ន្ធ ប្រទេសបញ្ជាទិញ ដើម្បីអន្តរាគមន៍បានចូលទីផ្សារក្នុងការប្រកួតប្រជែងផលិតផលរបស់ខ្លួន។ ជាពិសេសបាន រៀបចំកែសម្រួលលិខិតបទដ្ឋានគតិយុត្ត នីតិវិធីក្នុងការផ្តល់សេវា និងបច្ចេកទេសបានឆាប់រហ័សដល់អ្នកវិនិយោគ។

### ២.៩.ពង្រឹងកិច្ចសហប្រតិបត្តិការកម្រិតជាតិ និងអន្តរជាតិ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ តែងតែមានកិច្ចពិភាក្សាពិគ្រោះយោបល់ ចែករំលែកព័ត៌មាន ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទាំងកម្រិតថ្នាក់ជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរ-ជាតិនានាពាក់ព័ន្ធអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានសុខភាពសត្វ និង ផលិតកម្មសត្វ បាននឹងកំពុងសិក្សាគម្រោងមហាអនុតំបន់ទន្លេមេគង្គស្តីពីសុខភាពសត្វឆ្លងកាត់ព្រំដែន និងការជំរុញ

ខ្សែច្រវ៉ាក់ផលិតកម្មតម្លៃសត្វក្រោមការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានរយៈពេល៧ឆ្នាំ អនុវត្តចាប់ឆ្នាំ២០២២-២០២៨ ដែលមានទឹកប្រាក់ចំនួនសរុប៨០ ០០០ ០០០ ដុល្លារអាមេរិក គម្រោង "Establishing National Research Institute for Safety and Sanitation of Livestock Products in Cambodia" គាំទ្រដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) មានរយៈពេល៥ឆ្នាំ អនុវត្តចាប់ឆ្នាំ២០២៣-២០២៧ ដែលមានទឹកប្រាក់ចំនួនសរុប ៨ ០០០ ០០០ ដុល្លារអាមេរិក និងគម្រោង "Enhancing the Capacity of Animal Disease Diagnostic Laboratories in Cambodia and Myanmar" គាំទ្រដោយ ASEAN-China មានរយៈពេល១២ខែ ដែលមានទឹកប្រាក់ចំនួនសរុប១០ ៦៩៨ ៦៤៣ ដុល្លារអាមេរិក។

## VII. សេចក្តីសន្និដ្ឋាន

ក្នុងឆ្នាំ២០២១ នេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានពង្រឹងសមត្ថភាពអង្គភាពស្របតាមអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ និងប្រកាសលេខ៣៨១ ប្រក.កសក.ប ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧ លើការរៀបចំរចនាសម្ព័ន្ធដឹកនាំអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ ព្រមទាំងកសាងបាននូវលិខិតបទដ្ឋានតម្រូវនានាសម្រាប់ដំណើរការអង្គភាព ព្រមទាំងការចាត់ចែងវិធានគ្រប់គ្រងធនធានថវិកា និងធនធានមនុស្សបានយ៉ាងល្អប្រសើរ និងតាមការគ្រោងទុក។

ក្នុងឆ្នាំ២០២១ ប្រទេសកម្ពុជាក៏ដូចជាប្រទេសនានាក្នុងតំបន់ និងទូទាំងពិភពលោកបានទទួលរងនូវជំងឺផ្លូវដង្ហើមប្រភេទថ្មី (COVID-19) ដែលធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចជាតិទាំងមូល ជាពិសេសប្រជាពលរដ្ឋក្រីក្រ ដើម្បីចូលរួមកាត់បន្ថយនូវផលប៉ះពាល់ទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អទិភាពដល់វិស័យកសិកម្មដោយយកចិត្តទុកដាក់ដល់កសិករក្នុងការដាំដុះ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដោយមានការគាំទ្រថវិកាតាមកម្មវិធី ដៃគូរអភិវឌ្ឍន៍ ព្រមទាំងមានការចូលរួមពីវិស័យឯកជន និងអ្នកពាក់ព័ន្ធនានាបានធ្វើឱ្យផលិតកម្មសត្វមានការកើនឡើង។ កម្មវិធីតាមបែបប្រពៃណីស្ទើរតែទាំងអស់ត្រូវបានផ្អាក (ពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យ...) ធ្វើឱ្យការបរិភោគសាច់សត្វថយចុះ និងម្យ៉ាងទៀតពេលខ្លះធ្វើឱ្យប្រភេទសាច់សត្វមួយចំនួនមានតម្លៃខ្ពស់ និងពេលខ្លះក៏តម្លៃធ្លាក់ចុះផងដែរ។ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត បានសហការជាមួយការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានស្រុក អន្តរាគមន៍ចុះពិនិត្យព្យាបាល ចាក់វ៉ាក់សាំង យកវត្ថុវិភាគ អនុវត្តវិធានជីវសុវត្ថិភាព អនុវត្តវិធានការបសុព្យាបាល អប់រំណែនាំ ផ្សព្វផ្សាយបច្ចេកទេសក្នុងការទប់ស្កាត់ជំងឺសំខាន់ៗបានទាន់ពេលវេលាដូចជា ជំងឺប៉េស្តជ្រូកអាហ្វ្រិក ជំងឺដុំពកស្បែកគោ ក្របី និងជំងឺផ្តាសាយបក្សី។ ព្រឹត្តិការណ៍នេះបានប្រែក្លាយទៅជាកម្លាំងជំរុញឱ្យអ្នកចិញ្ចឹមសត្វមានបទពិសោធន៍ និងយល់ដឹងពីការជ្រើសរើសពូជល្អៗមកចិញ្ចឹមតាមរដូវកាលដែលធន់នឹងជំងឺ។

ក្នុងឆ្នាំ២០២១ នេះ ស្ថិតិសត្វចិញ្ចឹមសរុបកើនដល់ចំនួន៥៩,៩៦លានក្បាល ដែលអាចផ្គត់ផ្គង់សាច់សត្វគ្រប់ប្រភេទប្រមាណ៨៧% ស្មើនឹងចំនួន២៦៨ពាន់តោនលើតម្រូវការចំនួនសរុប៣១០ពាន់តោន។

ក្រៅពីលទ្ធផលពាក់ព័ន្ធទៅនឹងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ សម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនទៀត ឆ្លើយតបទៅនឹងទិសដៅអាទិភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានជាអាទិ៍៖

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍនវិស័យកសិកម្មឆ្នាំ២០១៩-២០២៣
- ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤
- ផែនការសកម្មភាពឆ្នាំ២០២២ សម្រាប់ថវិកាកម្មវិធីរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បទដ្ឋានគតិយុត្តមួយចំនួនក្រោមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

ការវិនិយោគក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ មានការកើនឡើងគួរឱ្យកត់សម្គាល់ដែលបច្ចុប្បន្នមានរោងចក្រផលិតចំណីសត្វចំនួន២១កន្លែង សត្តឃាតដ្ឋានបក្សីទំនើបចំនួន០១កន្លែង សត្តឃាតដ្ឋានគោទំនើបចំនួន

០១កន្លែង វិនិយោគចិញ្ចឹមគោយកទឹកដោះនិងផលិតទឹកដោះទំនើបចំនួន០១កន្លែង ការវិនិយោគចិញ្ចឹមសត្វនិងបង្កាត់ពូជសត្វ និងគម្រោងវិនិយោគមួយចំនួនទៀតកំពុងសិក្សាជាបន្តបន្ទាប់។

លទ្ធផលនៃកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ដូចជាអង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល និងផ្នែកឯកជនទទួលការគាំទ្រទាំងសម្ភារបច្ចេកទេស ថវិកា និងអ្នកជំនាញបច្ចេកទេស។ លើសពីនេះទៀតពីមួយឆ្នាំទៅមួយឆ្នាំការចិញ្ចឹមសត្វលក្ខណៈគ្រួសារត្រូវបានវិវត្តន៍ទៅជាការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្ម។

សមិទ្ធផលសំខាន់ៗដែលបានរៀបរាប់ខាងលើសម្រេចបាន គឺអាស្រ័យដោយមានគោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទាំងធនធានមនុស្ស សម្ភារនិងថវិកា និងការចូលរួមពីដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការជាតិ និងអន្តរជាតិ រួមជាមួយនឹងការខិតខំប្រឹងប្រែងបំពេញការងារយ៉ាងសកម្មរបស់មន្ត្រីរាជការនៅគ្រប់កម្រិត និងមានកិច្ចសហការពីអាជ្ញាធរមូលដ្ឋាន ព្រមទាំងមានការចូលរួមពីកសិករចិញ្ចឹមសត្វ ដើម្បីទទួលបានព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធបច្ចេកទេស បែបផែនផលិតកម្ម និងតម្រូវការទីផ្សារ។

ថ្ងៃសុក្រ ៤ រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**

**តាន់ ផាន់ណារ៉ា**

## VIII. បញ្ជីឧបសម្ព័ន្ធ

### តារាងបញ្ជីឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឧបសម្ព័ន្ធ | លេខឧបសម្ព័ន្ធ |
|---|---|---|
| ១ | ស្ថិតិផលិតកម្មសត្វលក្ខណៈគ្រួសារ ប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី១ |
| ២ | ស្ថិតិសត្វចតុប្បាទធំលក្ខណៈគ្រួសារឆ្នាំ២០២០១ | ឧបសម្ព័ន្ធទី១.១ |
| ៣ | ស្ថិតិសត្វចតុប្បាទតូចលក្ខណៈគ្រួសារឆ្នាំ២០២១ | ឧបសម្ព័ន្ធទី១.២ |
| ៤ | ស្ថិតិសត្វស្លាប និងឃ្មុំ លក្ខណៈគ្រួសារឆ្នាំ២០២១ | ឧបសម្ព័ន្ធទី១.៣ |
| ៥ | ប្រៀបធៀបស្ថិតិផលិតកម្មសត្វលក្ខណៈគ្រួសារឆ្នាំ២០២០-២០២១ | ឧបសម្ព័ន្ធទី១.៤ |
| ៦ | ស្ថិតិកសិដ្ឋាន និងផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មឆ្នាំ២០២១ | ឧបសម្ព័ន្ធទី២ |
| ៧ | ស្ថិតិកសិដ្ឋានចិញ្ចឹមគោ ក្របី លក្ខណៈពាណិជ្ជកម្មប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី២.១ |
| ៨ | ស្ថិតិកសិដ្ឋានចិញ្ចឹមសេះ ចៀម និងពពែលក្ខណៈពាណិជ្ជកម្មប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី២.២ |
| ៩ | ស្ថិតិកសិដ្ឋានចិញ្ចឹមជ្រូក លក្ខណៈពាណិជ្ជកម្មប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី២.៣ |
| ១០ | ស្ថិតិកសិដ្ឋានចិញ្ចឹមស្វា ទន្សាយ និងឃ្មុំ លក្ខណៈពាណិជ្ជកម្មប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី២.៤ |
| ១១ | ស្ថិតិកសិដ្ឋានចិញ្ចឹមមាន់លក្ខណៈពាណិជ្ជកម្មប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី២.៥ |
| ១២ | ស្ថិតិកសិដ្ឋានចិញ្ចឹមទា និងក្រួចលក្ខណៈពាណិជ្ជកម្មប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី២.៦ |
| ១៣ | ប្រៀបធៀបស្ថិតិកសិដ្ឋានចិញ្ចឹមគោ ក្របី ជ្រូក និងសត្វស្លាបលក្ខណៈពាណិជ្ជកម្មឆ្នាំ២០២០-២០២១ | ឧបសម្ព័ន្ធទី២.៧ |
| ១៤ | ប្រៀបធៀបស្ថិតិផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម ឆ្នាំ២០២០-២០២១ | ឧបសម្ព័ន្ធទី២.៨ |
| ១៥ | ស្ថិតិផលិតកម្មសត្វគ្រប់ប្រភេទ (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម) ឆ្នាំ២០២១ | ឧបសម្ព័ន្ធទី៣ |
| ១៦ | ប្រៀបធៀបស្ថិតិផលិតកម្មសត្វគ្រប់ប្រភេទ (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម) ប្រចាំឆ្នាំ ២០២០-២០២១ | ឧបសម្ព័ន្ធទី៤ |
| ១៧ | តារាងតាមដានចំណូលពីចលនាសត្វ និងផលិតផលសត្វប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី៥ |
| ១៨ | ស្ថិតិការបង្កាត់ពូជគោ និងជ្រូកដោយសិប្បនិម្មិតប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី៦ |
| ១៩ | ស្ថិតិដាំដុះដំណាំចំណីសត្វប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី៧ |
| ២០ | ព័ត៌មានតម្លៃសត្វ សាច់ និងផលិតផលសត្វប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី៨ |
| ២១ | ព័ត៌មានតម្លៃចំណីសត្វ សាច់ និងវត្ថុធាតុដើមប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី៩ |
| ២២ | ស្ថិតិក្រុមហ៊ុនផលិតចំណីសត្វប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី១០ |
| ២៣ | តារាងស្ថិតិចាត់ថ្នាំការពារជំងឺគោ ក្របី ឆ្កែ ឆ្មាប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី១១ |
| ២៤ | តារាងស្ថិតិចាក់ថ្នាំការពារជំងឺជ្រូក សត្វស្លាបប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី១២ |
| ២៥ | តារាងសកម្មភាពជីវសុវត្ថិភាពប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី១៣ |
| ២៦ | តារាងបច្ចុប្បន្នភាពភ្នាក់ងារសុខភាពសត្វភូមិទូទាំងប្រទេស | ឧបសម្ព័ន្ធទី១៤ |
| ២៧ | ស្ថិតិសត្តឃាតដ្ឋានដែលទទួលបានគោលការណ៍អនុញ្ញាតដោយអនុលោមតាមអនុក្រឹត្យ១០៨ និងវិនិយោគទូទាំងរាជធានី ខេត្ត | ឧបសម្ព័ន្ធទី១៥ |
| ២៨ | តារាងស្ថិតិសត្តឃាតដ្ឋាន និងចំនួនសត្វពិឃាតប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី១៦ |
| ២៩ | ស្ថិតិមន្ត្រីរាជការផលិតកម្ម និងបសុព្យាបាលទូទាំងប្រទេសប្រចាំឆ្នាំ២០២១ | ឧបសម្ព័ន្ធទី១៧ |

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ស្ថិតិផលិតកម្មសត្វ លក្ខណៈគ្រួសារ ប្រចាំឆ្នាំ២០២១

ឧបសម្ព័ន្ធទី១

| ល.រ | រាជធានី-ខេត្ត | គោ ក្របី | | | | សេះ | ដំរី | ចៀម | ពពែ | ជ្រូក | ស្វា | ទន្សាយ | ឆ្កែ | ឆ្មា | សត្វស្លាប | | | | ឃ្មុំ | សរុបរួម-ឯក (ឆ្កែ,ឆ្មា,ឃ្មុំ) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | គោ | ក្របី | សរុប | កម្លាំងអូសទាញ | | | | | | | | | | មាន់ | ទា | បក្សីផ្សេងៗ | សរុបសត្វស្លាប | | |
| A | B | 1 | 2 | 3=1+2 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17=14+15+16 | 18 | 19=Σ(1→18)-(4;12;13;18) |
| 1 | បន្ទាយមានជ័យ | 116,414 | 13,902 | 130,316 | 1,099 | 3 | 0 | 379 | 7,680 | 42,984 | 0 | 7 | 11,072 | 5,797 | 1,099,696 | 516,722 | 10,628 | 1,627,046 | 24 | 1,808,415 |
| 2 | បាត់ដំបង | 191,487 | 2,101 | 193,588 | 2,426 | 45 | 0 | 117 | 6,043 | 42,670 | 13 | 40 | 51,676 | 18,045 | 1,054,417 | 464,157 | 14,109 | 1,532,683 | 63 | 1,775,199 |
| 3 | កំពង់ចាម | 197,305 | 18,154 | 215,459 | 8,062 | 1,137 | 0 | 0 | 4,376 | 45,562 | 7 | 33 | 23,813 | 12,991 | 1,118,738 | 762,378 | 10,131 | 1,891,247 | 250 | 2,157,821 |
| 4 | កំពង់ឆ្នាំង | 182,462 | 29,145 | 211,607 | 5,106 | 15 | 0 | 0 | 2,564 | 148,972 | 22 | 0 | 109,371 | 51,596 | 2,329,238 | 194,340 | 4,767 | 2,528,345 | 0 | 2,891,525 |
| 5 | កំពង់ស្ពឺ | 270,141 | 891 | 271,032 | 1,532 | 0 | 0 | 0 | 792 | 20,216 | 0 | 0 | 70,114 | 27,714 | 1,095,674 | 97,998 | 5,886 | 1,199,558 | 0 | 1,491,598 |
| 6 | កំពង់ធំ | 164,711 | 50,989 | 215,700 | 6,612 | 82 | 0 | 246 | 139 | 53,380 | 0 | 0 | 40,530 | 24,305 | 926,626 | 457,264 | 689 | 1,384,579 | 0 | 1,654,126 |
| 7 | កំពត | 158,114 | 7,125 | 165,239 | 14,596 | 301 | 0 | 75 | 1,373 | 72,619 | 65 | 266 | 52,710 | 29,802 | 1,144,450 | 686,991 | 12,746 | 1,844,187 | 0 | 2,084,125 |
| 8 | កណ្តាល | 51,190 | 2,209 | 53,399 | 7,952 | 150 | 0 | 239 | 3,847 | 17,511 | 5 | 14 | 61,744 | 6,538 | 1,136,904 | 597,109 | 9,099 | 1,743,112 | 0 | 1,818,277 |
| 9 | កោះកុង | 9,867 | 9,095 | 18,962 | 658 | 0 | 0 | 110 | 472 | 2,959 | 0 | 0 | 17,778 | 4,232 | 195,290 | 24,643 | 3,787 | 223,720 | 0 | 246,223 |
| 10 | ក្រចេះ | 80,090 | 22,570 | 102,660 | 9,885 | 198 | 0 | 0 | 1,690 | 39,312 | 0 | 0 | 4,010 | 3,340 | 566,000 | 48,600 | 3,545 | 618,145 | 0 | 762,005 |
| 11 | មណ្ឌលគិរី | 23,339 | 16,923 | 40,262 | 9,781 | 20 | 34 | 21 | 191 | 10,617 | 21 | 27 | 1,542 | 695 | 69,510 | 6,877 | 190 | 76,577 | 0 | 127,770 |
| 12 | ភ្នំពេញ | 5,100 | 69 | 5,169 | 0 | 4 | 0 | 0 | 216 | 2,293 | 0 | 0 | 12,987 | 2,660 | 205,453 | 16,608 | 558 | 222,619 | 0 | 230,301 |
| 13 | ព្រះវិហារ | 80,020 | 10,244 | 90,264 | 7,845 | 0 | 0 | 17 | 1,804 | 205,575 | 7 | 30 | 202,382 | 25,234 | 861,868 | 61,767 | 1,092 | 924,727 | 0 | 1,222,424 |
| 14 | ព្រៃវែង | 359,078 | 16,507 | 375,585 | 114 | 88 | 0 | 75 | 2,476 | 28,768 | 17 | 6 | 83,269 | 55,259 | 2,820,359 | 1,060,177 | 25,941 | 3,906,477 | 0 | 4,313,492 |
| 15 | ពោធិ៍សាត់ | 94,401 | 44,382 | 138,783 | 24,672 | 4 | 0 | 111 | 137 | 22,577 | 0 | 0 | 42,992 | 21,725 | 1,122,178 | 327,041 | 3,052 | 1,452,271 | 0 | 1,613,883 |
| 16 | រតនគិរី | 37,138 | 11,830 | 48,968 | 44 | 4 | 3 | 0 | 889 | 17,029 | 5 | 51 | 12,354 | 6,743 | 170,995 | 27,655 | 3,047 | 201,697 | 0 | 268,646 |
| 17 | សៀមរាប | 212,133 | 32,767 | 244,900 | 7,915 | 35 | 12 | 17 | 575 | 57,660 | 0 | 0 | 180,350 | 30,830 | 1,464,850 | 726,350 | 7,097 | 2,198,297 | 0 | 2,501,496 |
| 18 | ព្រះសីហនុ | 7,916 | 4,902 | 12,818 | 3,493 | 0 | 0 | 0 | 110 | 1,550 | 0 | 0 | 25,523 | 2,200 | 67,974 | 55,821 | 4,655 | 128,450 | 0 | 142,928 |
| 19 | ស្ទឹងត្រែង | 31,091 | 37,193 | 68,284 | 7,340 | 0 | 0 | 49 | 1,261 | 34,812 | 0 | 0 | 25,653 | 4,771 | 182,171 | 26,576 | 491 | 209,238 | 0 | 313,644 |
| 20 | ស្វាយរៀង | 190,227 | 70,968 | 261,195 | 16,453 | 0 | 0 | 10 | 39 | 73,990 | 0 | 42 | 10,840 | 7,060 | 1,663,242 | 205,932 | 11,399 | 1,880,573 | 26 | 2,215,849 |
| 21 | តាកែវ | 309,076 | 4,002 | 313,078 | 5,500 | 149 | 0 | 0 | 1,510 | 245,156 | 0 | 0 | 92,000 | 47,600 | 3,054,269 | 956,260 | 0 | 4,010,529 | 0 | 4,570,422 |
| 22 | ឧត្តរមានជ័យ | 43,738 | 5,009 | 48,747 | 4,359 | 0 | 0 | 52 | 510 | 26,617 | 0 | 0 | 19,915 | 11,070 | 306,622 | 42,773 | 5,753 | 355,148 | 0 | 431,074 |
| 23 | កែប | 16,423 | 825 | 17,248 | 4,606 | 10 | 0 | 0 | 255 | 4,509 | 0 | 0 | 1,004 | 460 | 93,576 | 11,498 | 0 | 105,074 | 0 | 127,096 |
| 24 | ប៉ៃលិន | 12,490 | 7 | 12,497 | 0 | 8 | 0 | 475 | 557 | 5,929 | 4 | 30 | 2,283 | 0 | 317,076 | 11,946 | 1,901 | 330,923 | 119 | 350,423 |
| 25 | ត្បូងឃ្មុំ | 108,800 | 20,600 | 129,400 | 11,500 | 1,330 | 0 | 500 | 3,000 | 26,900 | 0 | 0 | 66,300 | 5,600 | 1,148,700 | 138,060 | 9,970 | 1,296,730 | 1 | 1,457,860 |
| | **សរុប** | **2,952,751** | **432,409** | **3,385,160** | **161,550** | **3,583** | **49** | **2,493** | **42,506** | **1,250,167** | **166** | **546** | **1,222,212** | **406,267** | **24,215,876** | **7,525,543** | **150,533** | **31,891,952** | **483** | **36,576,622** |

ថ្ងៃព្រហស្បតិ៍ ១១រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

បានឃើញ និងឯកភាព
អគ្គនាយក

តាន់ ផាន់ណារ៉ា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានផលិតកម្មសត្វ

អ្នកធ្វើតារាង

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ស្ថិតិសត្វចតុប្បាទធំ លក្ខណៈគ្រួសារ ប្រចាំឆ្នាំ២០២១

ឧបសម្ព័ន្ធទី១.១

| ល.រ | រាជធានី-ខេត្ត | គោ (ក្បាល) | | | | | | | ក្របី (ក្បាល) | | | | | | សរុប គោ-ក្របី | សរុប កម្លាំងអូសទាញ | សេះ (ក្បាល) | | | | | | ដំរី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បា | ៣ឆ្នាំឡើង | | ៣ឆ្នាំចុះ | | សរុប | កម្លាំងអូសទាញ | ៣ឆ្នាំឡើង | | ៣ឆ្នាំចុះ | | សរុប | កម្លាំងអូសទាញ | | | ៣ឆ្នាំឡើង | | ៣ឆ្នាំចុះ | | សរុប | កម្លាំងអូសទាញ | |
| | | | ឈ្មោល | ញី | ឈ្មោល | ញី | | | ឈ្មោល | ញី | ឈ្មោល | ញី | | | | | ឈ្មោល | ញី | ឈ្មោល | ញី | | | |
| 1 | បន្ទាយមានជ័យ | 966 | 18,666 | 36,354 | 26,520 | 33,908 | 116,414 | 539 | 2,567 | 4,315 | 3,270 | 3,750 | 13,902 | 560 | 130,316 | 1,099 | 3 | 0 | 0 | 0 | 3 | 0 | 0 |
| 2 | បាត់ដំបង | 708 | 34,647 | 60,996 | 41,978 | 53,158 | 191,487 | 2,333 | 416 | 675 | 494 | 516 | 2,101 | 93 | 193,588 | 2,426 | 22 | 17 | 2 | 4 | 45 | 29 | 0 |
| 3 | កំពង់ចាម | 550 | 45,949 | 65,602 | 40,199 | 45,005 | 197,305 | 6,625 | 3,734 | 7,430 | 3,007 | 3,983 | 18,154 | 1,437 | 215,459 | 8,062 | 429 | 336 | 175 | 197 | 1,137 | 765 | 0 |
| 4 | កំពង់ឆ្នាំង | 480 | 35,142 | 59,555 | 40,198 | 47,087 | 182,462 | 4,624 | 5,030 | 10,714 | 6,428 | 6,973 | 29,145 | 482 | 211,607 | 5,106 | 7 | 3 | 3 | 2 | 15 | 0 | 0 |
| 5 | កំពង់ស្ពឺ | 1,389 | 53,396 | 98,202 | 53,214 | 63,940 | 270,141 | 1,384 | 170 | 235 | 268 | 218 | 891 | 148 | 271,032 | 1,532 | 0 | 0 | 0 | 0 | 0 | 5 | 0 |
| 6 | កំពង់ធំ | 293 | 42,476 | 42,564 | 36,517 | 42,861 | 164,711 | 4,247 | 10,677 | 12,974 | 11,334 | 16,004 | 50,989 | 2,365 | 215,700 | 6,612 | 69 | 8 | 2 | 3 | 82 | 77 | 0 |
